D59682

S-485

TSL

Sèm Ry dit Roeun

[illegible] សែម រី ហៅ រឿន

[illegible] 270 [illegible] 340

ចូល 20-11-78

25 aug

2.12.78

ចម្លើយ របស់ឈ្មោះ ថែម.ទី ហៅ ទៀន

ជាយុទ្ធជននៅក្នុងកងពិសេសរបស់ វរៈសេនាធំ២៧០ កងពល៣៤០

មុនអង្គការចាប់ខ្លួន នៅកងទ័ពកប់ត្រូវ

---

អំពី

ប្រវត្តិសកម្មភាពក្បត់ បក្សផ្ទាល់

ធ្វើនៅថ្ងៃទី ១.១២.១៩៧៨

ខ្ញុំសូមរាយការណ៍ជូនអង្គការអំពីប្រវត្តិសកម្មភាព

ក្បត់របស់ខ្ញុំ

ខ្ញុំឈ្មោះ ស៊ែម . រី ហៅ វឿន មុនអង្គការចាប់ខ្លួនខ្ញុំជាយុទ្ធជននៅកងពិសេសវរៈសេនាធំលេខ ២៧០ របស់កងពលលេខ ៣៥០ ប្រចាំនៅសមរភូមិ ត្រពាំងព្រាម ភូមិភាគបូព៌ា ។ ខ្ញុំមានអាយុ ២៥ ឆ្នាំ ភេទប្រុស ជាតិខ្មែរ។ ខ្ញុំមានគ្រួសាររួចហើយ ។ កើតនៅភូមិស្វែររៀន ឃុំបឹងវែង ស្រុកព្រាម តំបន់ ២៤ ភូមិភាគបូព៌ា ។ ខ្ញុំមានបងប្អូន៨នាក់ ប្រុស៥នាក់ ស្រី៣នាក់ ។ ឪពុកខ្ញុំ - ឈ្មោះ ព្រុំ - ស៊ែម ។ ម្ដាយឈ្មោះ អន - មិន បច្ចុប្បន្ននេះនៅសហករណ៍ ភូមិកោះកុក ឃុំកោះកុក ស្រុកពាមជរ តំបន់ ២៤ ។

តាំងពីដឹងក្ដីមក ខ្ញុំរស់នៅជាមួយឪពុកម្ដាយរហូត ។ ដល់ឆ្នាំ ១៩៦៣ ឪពុកម្ដាយខ្ញុំឲ្យចូលរៀននៅសាលាវត្តប្រែស្រ ពីថ្នាក់ទី១២ ដល់ថ្នាក់ទី ១១ ។ ដល់ឆ្នាំ ១៩៦៦ ខ្ញុំឈប់រៀនមកនៅជាមួយឪពុកម្ដាយវិញ ។ តាំងពីពេលនោះមកក្រុមគ្រួសារខ្ញុំជីវភាពធូរស្រាលដែរ ព្រោះឪពុកខ្ញុំជាអ្នកចោរលួចគោក្របីរបស់ប្រជាជនពីដើម ។ ហើយគាត់បានយករបស់ដែលលួចបាននេះទៅលក់នៅស្រុកយួន បានជាបន្តបន្ទាប់ទៀត ដូច្នេះជីវភាពមិនខ្វះអីទាំងអស់ ។ ដល់ក្រោយមកទៀតឪពុកខ្ញុំ ធ្វើជាមេ ១០ខ្នងទៀតកាលនៅក្នុងឆ្នាំ ១៩៦៦ ។ តាំងពីពេលនោះមកឪពុកខ្ញុំគាត់បានទាក់ទងជាមួយមេស្រុក ភួង ជាប់ ហើយមេស្រុកភួងនេះបានចាត់តាំងឪពុកខ្ញុំដើរគំរាមកំហែងទារពន្ធដារពីប្រជាជន មកឲ្យមេស្រុកភួងនេះ ដើម្បីមានការធ្វើនឹងគេទៀត ។ ដល់ឆ្នាំ ១៩៦៧នេះឪពុកខ្ញុំបានជាប់ជិតស្និតជាមួយមេស្រុកភួង កាន់

ខ្លាំងឡើងជាងមុនទាំងអស់ ។ ក្រៅពីមេស្រុក ភ្នំ ទៀត មានអ្នកដើរទារពន្ធដារពីសង្គមចាស់ឈ្មោះ តាឃីវ - ណោ ទាំងពីរនាក់នេះនៅជិតផ្ទះខ្ញុំ ។ តាំងពីពេលនោះមក ឪពុកខ្ញុំបានទាក់ទងអ្នកទាំងអស់នោះជាប់ ។ ហើយគាត់មិនសូវនៅផ្ទះទេ មានគ្នាគាត់ទាំងបីនាក់នោះ ដើរតែលួចគោក្របីរបស់ប្រជាជន ទេនៅស្រុកផ្សេងៗទៀត ព្រោះគាត់មិនសូវខ្លាចអ្នកណាអាងលើមេស្រុកភ្នំស្រាប់ ដល់ឆ្នាំ ១៩៦៨នេះ មេស្រុកភ្នំបានមកលេងផ្ទះខ្ញុំម្ដងទៀត ពេលមកដល់ដំបូង គាត់មិនទាន់ធ្វើអីទេ ដល់យូរបន្តិចគាត់បានហៅ តាឃីវ - ណោ - និងពួខ្លីពីរនាក់ទៀត-ឈ្មោះ យើន - ផាន់ - ទៅប្រជុំនៅចុងភូមិខាងក្រោយផ្ទះរបស់ខ្ញុំ ។ ការប្រជុំខ្ញុំមិនដឹងអីទេ ព្រោះគាត់មិនហៅខ្ញុំទៅ ។ ការប្រជុំគ្នានេះអស់រយៈមួយព្រឹក ទើបឃើញឪពុកខ្ញុំមកវិញ ហើយអ្នកចូលរួមប្រជុំជាមួយគាត់នោះ ត្រូវបែកគ្នាទាំងអស់ ។ ពេលដែលមកដល់គាត់មិនទាន់ហាមាត់ករអីទេ ។ ដល់ក្រោយមកទៀត-នៅក្នុងឆ្នាំ ១៩៦៨នេះដដែល ឪពុកខ្ញុំបានហៅបងខ្ញុំឈ្មោះ មី . រីន . មឿន ឯម្ដាយខ្ញុំក៏ចូលក្នុងការអប់រំនេះដែរ ។ គាត់បាននិយាយអប់រំថា អញធ្វើជាភ្នាក់ងារឈ្លបសម្ងាត់ឱ្យមេស្រុកភ្នំហើយ អាណាសុខចិត្តដើរតាមអញទេ បើមិនដើរ-តាមទេប្រយ័ត្នទៅថ្ងៃក្រោយអញសម្លាប់ចោលទាំងអស់ ។ ឪពុកខ្ញុំបន្តទៀតថាកូនទាំងអស់ត្រូវតែស្ដាប់ពុក ដើម្បីទៅថ្ងៃអនាគតភ្លឺស្វាងដូចគេ ហើយមានបុណ្យសក្ដិប្រាក់ខែទៀតនៅក្នុងគ្រួសារយើង ។ ពេលនោះបងខ្ញុំឈ្មោះ មី ឆ្លើយទៅប្រាប់គាត់វិញថា ឱ្យតែពុកឱ្យធ្វើអី យើងខ្ញុំកូនធ្វើតាមទាំងអស់ ។ ឪពុកខ្ញុំគាត់ថា ឥឡូវនេះយើងត្រូវធ្វើភ្នាក់ងារឈ្លបសម្ងាត់ឱ្យមេស្រុក ភ្នំ ចុះ ព្រោះគេថា

ឲ្យតែអ្នកណាធ្វើការងារគិញ្ញសម្ងាត់នេះបានល្អ គេឲ្យយើងធ្វើជាស្អីមួយមិនខានទេ ។ ហើយភារៈកិច្ចដែលពុកឲ្យកូនធ្វើនេះគឺ ត្រូវខិតខំស៊ើបការតាមដានខ្មែរក្រហមភូមិយើងនេះ កុំឲ្យវាចូលមកឃោសនាប្រជាជនប្រឆាំងនឹងសីហនុ ។ ម្យ៉ាងទៀត-កូនឯងទាំងអស់ឃើញហើយ ត្រូវរាយការណ៍ប្រាប់ពុក ដើម្បីពុកទៅរាយការប្រាប់មេស្រុក យើងបានប្រាក់ខែថែមទៀត ។ ក្រៅពីដើរស៊ើបការ ត្រូវខិតខំ កសាងកម្លាំងគិញ្ញសម្ងាត់ឲ្យបានច្រើន នឹងដើរបំផុសចលនាប្រជាជននៅភូមិយើង នឹងនៅតាមភូមិជិតយើង កុំឲ្យគេស្រឡាញ់ខ្មែរក្រហម កូនឯងទាំងអស់គ្នាត្រូវលើកឡើងបំផុសថា ខ្មែរក្រហមដើរតែកាប់សម្លាប់ប្រជាជន មួយទៀតត្រូវនិយាយអំពីជីវភាពរបស់ខ្មែរក្រហមលំបាក ។ ម្យ៉ាងទៀតកូនទាំងអស់ត្រូវបំផុសចលនាលើពីរបបសីហនុ ឲ្យប្រជជជនគេស្រឡាញ់ ដើម្បីអូសទាញគេមកខាងយើង ។ ក្រៅពីនេះពុកខ្ញុំប្រាប់ថា កូនឯងដើរស៊ើបការរកខ្មែរក្រហមចុះ ឳពុកមិនបាននៅ ផ្ទះទេ ព្រោះមេស្រុកភួងបបួលពុកដើរលួចគោក្របីទៅលក់នៅស្រុកយួន នឹងទាក់-ទងយួនទៀត ។ ពេលដើរយកការ យើងត្រូវទិញនំបណើដើរលក់ពីភូមិមួយទៅភូមិមួយខ្លួងខ្លួន ការពិតរបស់កូនគឺដើរស៊ើបការពិនិត្យមើលខ្មែរក្រហម ។ រួចហើយគាត់បានប្រាប់កម្លាំងឲ្យខ្ញុំទាក់ទង ពេលដែលខ្ញុំដើរស៊ើបការឃើញខ្មែរក្រហមហើយ-បើមិនឃើញគាត់នៅផ្ទះ រាយការណ៍ឲ្យកម្លាំងគាត់ទៀតមានឈ្មោះ :

១ -ភួង អតីតៈមេស្រុកបាភ្នំ រត់ចេញពីស្រុកបាភ្នំតាំងពីឆ្នាំ ១៩៧៣ បច្ចុប្ប-ក្តាប់មិនបាន ។

២ - ណោ អតីតៈអ្នកដើរទាពន្ធដារ កាលពីឆ្នាំ ៧៣ អង្គការចាប់ទៅអប់រំ ។ បច្ចុប្បន្នជាប្រជាជននៅសហករណ៍ពូភាឡាក់ ឃុំបឹងដែ ស្រុកបាភ្នំ ។

៣- ឈឿន  អតីតៈអ្នកលក់ដូរនៅស្រុកឃ្មួន  កាលពីឆ្នាំ ៧០ប្រធានភូមិស្លែទៀន

បច្ចុប្បន្នប្រជាជននៅសហករណ៍ភូមិស្លែទៀន  ស្រុកបាភ្នំ តំបន់២៤។

៤- តាឃឿរ អតីតៈអ្នកទារពន្ធដារពីសង្គមចាស់  កាលពីឆ្នាំ ៧៣ស្លាប់ហើយ ។

៥- ផាន់ អតីតៈចោរលួចគោក្របីជាមួយពុកខ្ញុំដែរ  បច្ចុប្បន្នប្រជាជន - នៅស្រុកពាមជរ  តំបន់ ២៤  ។

រួចហើយគាត់បានប្រាប់ខ្ញុំទាំងអស់គ្នាថា  កម្លាំងទាំងអស់នេះជាអ្នកដឹកនាំមួយសំខាន់ដែរ ប៉ុន្តែមិនទាន់មានបក្សកងរឹងមាំ ។ ផ្ទុយទៅនេះកម្លាំងនេះ  បើកូនឯងដើរស៊ើប ការបាន  រាយការណ៍ឱ្យអ្នកណាក៏បានដែរ  ចាំឪពុកប្រាប់ទៅកម្លាំងទាំងអស់នេះ ។ រួចហើយគាត់ក៏ដើរចេញពីខ្ញុំទាំងអស់គ្នា ។  តាំងពីពេលពុកខ្ញុំអប់រំឱ្យដើរយកការ មក ខ្ញុំនឹងបងរបស់ខ្ញុំ៣នាក់ គឺមិនបាននៅផ្ទះទេ ព្រឹកទៀងដើរ ពេលយប់ខ្លះ - ដែភ្លឺដើរទៀត  ដើម្បីយកការឱ្យបានសំរេចតាមឪពុកខ្ញុំប្រាប់ ។ ការដើរយកការ អស់មួយរយៈនៅមិនឃើញខ្មែរក្រហម  ព្រោះពេលនោះស្រុកខ្ញុំមិនទាន់មានចូលទេ។

ក្រោយពីដើរស៊ើបការមិនបានសំរេចមក  បងខ្ញុំនឹងខ្ញុំបានដើរបំផុសចលនាប្រជាជននៅតាមភូមិ  ឱ្យគេស្រឡាញ់របបសីហនុ  ការបំផុសចលនានេះប្រជាជនមានជំនឿ  ហើយខ្លះស្អប់ខ្មែរក្រហមជេប្រទុចផ្លាស់សារខ្មែរក្រហម ។  ក្រោយពីនេះ មកខ្ញុំនឹងបងបានទៅទាក់ទងជាមួយញូឿន  ដើម្បីឱ្យគាត់ស្គាល់ខ្ញុំជាកម្លាំងរបស់ឪពុក - ពេលនោះខ្ញុំជាមួយបងខ្ញុំទាំងអស់ទៅ  ពេលទៅដល់ផ្ទះគាត់ឃើញមានឈ្មោះ ផាន់ នៅទីនោះដែរ  គាត់បានសួរខ្ញុំ  ខ្ញុំឆ្លើយប្រាប់គាត់ថា  ខ្ញុំមកទាក់ទងជាមួយ ញូឿន ឯង  តាមឪពុកខ្ញុំប្រាប់ថា  ពូឯងជាកម្លាំងរបស់គាត់  ពេលនេះញូឿនប្រាប់ខ្ញុំថាគាត់ ជាកម្លាំងរបស់ពុកខ្ញុំ  ពេលនោះខ្ញុំប្រាប់ឱ្យគាត់ទទួលបងខ្ញុំនឹងខ្ញុំជាកម្លាំងរបស់គាត់ ។

រួចហើយ ខ្ញុំត្រឡប់មកផ្ទះវិញ ។ នៅក្នុងឆ្នាំនេះគ្មានតាមឃើញខ្មែរក្រហមអីទេ គ្រាន់តែបានដើរបំផុសចលនាប្រជាជនប៉ុណ្ណឹង ។

ដល់ឆ្នាំ ១៩៦៩ និងដើមឆ្នាំ ១៩៧០ ការធ្វើសកម្មភាពតាមដាន និងទាក់-ទងស្ទាបផ្សាញកម្លាំងខ្មែរក្រហមមិនបាន ព្រោះសភាពការណ៍ទូទៅមានហើយខ្មែរក្រហម តែនៅក្នុងស្រុករបស់ខ្ញុំគឺដូចពីឆ្នាំ ១៩៦៨ដែរ មិនទាន់មានចូលទេ ។ គឺបានតែឃោសនាប្រជាជនប៉ុណ្ណឹង ដូចឆ្នាំ ១៩៦៨ដែរ ។ ដល់ពាក់កណ្ដាលឆ្នាំ ៦៩ ឪពុកខ្ញុំបានណែនាំខ្ញុំ-និងបងខ្ញុំថា គាត់ឃើញដូច្នេះគ្មានអ្នកណាគេស៊ីទេ ហេតុដេះ កូនឯងត្រូវទៅទាក់ទងមេស្រុកភ្លូង ដើម្បីដើរលួចគោក្របីទៅលក់នៅស្រុកយួន បានលុយចាយទៀត ។ រួចហើយខ្ញុំក៏ដើរចេញបាត់ ពេលដែលគាត់ណែនាំនេះខ្ញុំនិងខ្ញុំ-មិនហ៊ានទៅលួចទេ ព្រោះខ្លាចប្រជាជនកាប់ ខ្ញុំនៅតែដើរធ្វើសកម្មភាពក្នុងភូមិប៉ុណ្ណឹង ក្នុងឆ្នាំ១៩៦៩នេះ កម្លាំងរបស់ខ្ញុំកសាងកម្លាំងបាន ៦នាក់មានឈ្មោះ ៖

១ - លុន អតីតៈធ្វើស្រែ បច្ចុប្បន្នជាប្រជាជននៅភូមិរសីក្លែកឃុំបឹង ថ្មីជ-ស្រុកបាភ្នំ តំបន់ ២៤ ភូមិភាគបូពា៌ ។

២ - ឃួន អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជននៅសហករណ៍ភូមិកោះកុកស្រុកពាមជរ តំបន់ ២៤ ។

៣ - ម៉ន អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជននៅសហករណ៍ភូមិប្រស្រែ ស្រុកបាភ្នំ តំបន់ ២៤ ។

៤ - មាន អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជននៅសហករភូមិប្រស្រែ ស្រុកបាភ្នំ តំបន់ ២៤ ។

៥ - ប្រក់ អតីតៈធ្វើស្រែ កាលពីឆ្នាំ ៧៣ ស្លាប់ហើយ ដោយឈឺ ។

៦ - ឃ៉ង អតីតៈធ្វើស្រែ បច្ចុប្បន្នស្លាប់ហើយ ។

កម្លាំងទាំងអស់នេះ ពួកខ្ញុំបានរាយការណ៍ប្រាប់ទៅពុកខ្ញុំ ពុកខ្ញុំបានរាយការណ៍ប្រាប់មេស្រុកភួងហើយ ។

ដល់ឆ្នាំ ១៩៧០នេះ សភាពការណ៍ជិតកើតរដ្ឋប្រហា ពេលនោះឪពុកខ្ញុំបានរៀបចំការគ្រួសារឱ្យបងខ្ញុំទាំង ហើយបងខ្ញុំមិនយកគ្រួសារនៅស្រុកឯងទេ នៅស្រុកគេទាំងអស់ ។ ក្រោយរដ្ឋប្រហារភ្លាមហើយ មេស្រុកភួង បានហៅពុកខ្ញុំ ខ្ញុំ - ញ៉ឹម - តាយីវ - ណោ - ផាន់ - ពេលទៅដល់សាលាស្រុក ហើយមេស្រុកភួង-បានហៅពុកខ្ញុំ និងគ្នាខ្ញុំទាំងអស់ឡើងទៅលើផ្ទះសម្ងាត់របស់គាត់ ។ រួចហើយមេស្រុកភួងបានបើកអង្គប្រជុំថា ឥឡូវនេះសភាពការណ៍កាន់តែមិនស្រួលហើយ បដិវត្តមានចូលភូមិខ្លះពុះហើយ ខ្ញុំសុំស្នើបងប្អូនទាំងអស់គ្នាថា ត្រូវខំរកវិធីកសាងកម្លាំងបង្កប់នៅតាមភូមិ.ឃុំឱ្យបានច្រើនថែមទៀត ។ មយ៉ាងទៀតត្រូវបំផុសចលនាឱ្យប្រ-ជាជនប្រឆាំងនឹងពួកនេះ កុំឱ្យគេមានជំនឿមកលើខ្មែរក្រហម ត្រូវបំផុសចលនានឹងឱ្យគេមកជឿយើងវិញ ។ មួយទៀតបើមានខ្មែរក្រហមចូលមកបោះនៅក្នុងភូមិ យើងត្រូវបំផុសឱ្យប្រជាជនគេប្រឆាំងឡើង ឱ្យគេធ្វើសកម្មភាពអុកឡុកឱ្យដាប់ ចុះចំនួនទទួលនឹងការបំផុសចលនានេះ ត្រូវរាយការណ៍មកប្រាប់ខ្ញុំ ដើម្បីឱ្យ-ទាហានទៅធ្វើសកម្មភាពបាញ់បង្ក្រាបចេញពីភូមិ បន្ទាប់ពីលើកផែនការនេះមកមេស្រុកបានលើកឡើងថា ក្រៅពីនេះត្រូវធ្វើសកម្មភាពបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាជនទៀត យើងទំលាក់រឿងនេះលើខ្មែរក្រហម ឃោសនាបំភាន់ភ្នែកប្រជាជន-ឱ្យគេប្រឆាំងខ្មែរក្រហមវិញ ។ រួចហើយក៏បែកគ្នាទៅតាមកន្លែងនិមួយរបស់ខ្លួន

ក្រោយពីបានទទួលផែនការនេះមក ខ្ញុំ - ញូអ៊ីន - តាយីវ - ផាន់ - បានចុះទៅធ្វើ - សកម្មភាព ពេលនោះពួកខ្ញុំបាន ទៅបំផុសចលនាឱ្យប្រជាជនរត់នៅភូមិប្រទែប្រអស់ ៦គ្រួសារ គាត់រត់ចេញពីភូមិទៅស្រុកយួនខ្លះ ខ្លះទៅចូលទាហាន ដោយខ្ញុំ បំភ័យថាគាត់នេះធ្វើគិញ ដូច្នេះអង្គការចាប់មិនរត់ចេញទេ រួចហើយប្រជាជ ន នោះរត់ទៅ ។ ក្រោយពីនេះមកទៀត ខ្ញុំបានទៅលួចកាប់ភ្លឺស្រែរបស់ប្រជាជនដែលទើបស្ទូងហើយអស់ប្រវែល ៣ស្រែ ត្រូវវងាច់ខូចអស់ ព្រោះម្ចាស់គាត់មិន - មកមើល ។

ដល់ពាក់កណ្តាលឆ្នាំ ១៩៧០ អង្គការបានចាត់តាំងញូអ៊ីនជាប្រធានភូមិ នៅ ភូមិស្នែរៀន ។ ក្រោយការចាត់តាំងនេះមក ខ្ញុំបានដើរស៊ើបការម្តង ដើម្បី រកបដិវត្ត ព្រោះបដិវត្តពេលនោះមិនដែលនៅមន្ទីរណោះច្បាស់ទេ បើរកឃើញ ខ្ញុំទៅរាយការណ៍ប្រាប់មេស្រុក ពិតជាបានលុយចាយទៀត ។ ការដើរនេះខ្ញុំ - រកមូលដ្ឋានបដិវត្តមិនបានត្រង់ណាមួយសំខាន់សោះ គ្រាន់តែឃើញពីចម្ងាយណោះ ស្លែក ទៀងរត់ ឬមួយដកកងទ័ពចេញពីទីនេះបាត់ ។ ដូច្នេះផែនការដែលត្រូវរាយ ការណ៍ទៅឱ្យមេស្រុកភ្លូងមិនបាន ។ ដល់ឆ្នាំ ១៩៧១ មេស្រុកភ្លូង ត្រូវដាច់ - ការទាក់ទងគ្នា ព្រោះអង្គការលែងឱ្យដើរសេរីដូចមុនទៀត អ្នកដែលដើរទាន ពន្ធដា កំខ្ញុំមិនបានទៅទាក់ទងដែរ ។ ព្រោះពេលនោះអង្គការឲ្យសំអាត គិញនៅពេលនោះ បន្ទាប់មកឪពុកខ្ញុំអង្គការចាប់យកទៅដែរ ទាល់តែឆ្នាំ ៧៧ ក្រោយពីមានសភាពការណ៍ផ្ទុះនៅបូពាំ ដែលយួនវីវី ពេលនោះឪពុកខ្ញុំរួចមកនៅ ផ្ទះ ពេលនោះពួកខ្ញុំមិនហ៊ានធ្វើសកម្មភាពអីខ្លាំងទេ ប៉ុន្តែឈ្មោះពួកខ្ញុំធ្វើនៅតែ -

ធ្វើទាំងអស់ ។ ក្រោយមកទៀតញូឃឿន បានហៅខ្ញុំទៅអប់រំ ពេលខ្ញុំទៅដល់ឃើញ
ឃើញមានឈ្មោះ យាក់-មិត-ញ៉ាំ-ផាន់- គាត់បានអប់រំថា ក្រោយពីអង្គការ
ចាប់កម្លាំងយើងមកនេះ មានសភាពប្រចបូកប្រចល់មែនទែន ដូច្នេះយើងកុំធ្វើសកម្ម
ភាពចំហរពេក ធើមីឱ្យពុករបស់មិត្តរី អង្គការចាប់ ព្រោះគាត់ធ្វើសកម្មភាពចំហ រ
ពេក ។ ដូច្នេះសព្វថ្ងៃនេះអង្គការកំពុងតែតាមដានរកចាប់កម្លាំងគិញ្ញសម្ងាត់របស់
យើង ពីពេលនេះទៅមិត្តត្រូវចេះលក្ខការណ៍ ។ ប៉ុន្តែទោះសភាពការណ៍យ៉ាង-
នេះក៏ដោយត្រូវតែបំពេញឱ្យបានសំរេច ។ រួចពីការណែនាំមកញូឃឿនបានលើកផែន
ការអនុវត្ត : ទី១ ត្រូវកសាងកម្លាំងបង្កប់នៅក្នុងភូមិឱ្យបានច្រើន ពិសេសយើង
ត្រូវកសាងយុវជននៅក្នុងភូមិ ដើម្បីត្រៀមយូរអង្វែងទៀត ។ ទី២ យើងត្រូវ
ធ្វើសកម្មភាពបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាជនទៀត ធ្វើឱ្យប្រជាជនអស់-
ជំនឿលើបដិវត្ត ។ ទី ៣ត្រូវទាក់ទងគ្នាធ្វើសកម្មភាពឱ្យដាច់ និងទាក់ទងកម្លាំង
ពីមួយទៅមួយឱ្យបានថែមទៀត ពេលមានសភាពការណ៍យើងទាំងអស់គ្នាងើង ។
ក្រោយពីគាត់ណែនាំអញ្ចឹងមក ញូឃឿនបានចាត់តាំងឱ្យខ្ញុំទៅនៅអង្គភាពយុវជនភូមិ-
ស្នែងរៀន ដើម្បីអង្គការត្រូវការទៅឈាមកណាពេលមានការ ។ បន្ទាប់មកញូ
ឃឿនបានឱ្យទទួលនាមកម្លាំងរបស់គាត់ឱ្យខ្ញុំទាក់ទងធ្វើសកម្មភាពគឺ :

១-មិត អតីតៈធ្វើស្រែ កាលពីឆ្នាំ ៧៣មានគ្រួសារ បច្ចុប្បន្ននៅ-
សហករណ៍ភូមិស្វាយភ្លោះ ស្រុកតាមដរ តំបន់ ២៥ ។

២-លាក់ អតីតៈធ្វើស្រែ កាលឆ្នាំ១៩៧១នៅយុវជនភូមិដូចគ្នា បច្ចុប្បន្ន
ប្រជាជននៅសហករណ៍ភូមិស្វាយភ្លោះ ស្រុកតាមដរ តំបន់២៥។

៣- ឆុន   អតីតៈធ្វើស្រែ ឆ្នាំ៧៨ នៅយុវជនភូមិដូចខ្ញុំដែរ  បច្ចុប្បន្ននៅ
ប្រជាជននៅសហករណ៍ភូមិប្រស្រែ  ស្រុកបាភ្នំ  តំបន់២៤  ។

៤- សាន់  អតីតៈធ្វើស្រែ បច្ចុប្បន្ន ស្លាប់ហើយ  ។

៥- ហាន  អតីតៈធ្វើស្រែ  បច្ចុប្បន្នស្លាប់ហើយ  ។

ក្រោយពីបានទទួលការណែនាំ  និងឧទេសនាមកម្លាំងឱ្យខ្ញុំស្គាល់នេះមក  ក៏បែកគ្នា-ទៅតាមកន្លែងរបស់ខ្លួន  ។  ដោយឡែកតែខ្ញុំបានមកនៅអង្គភាពយុវជនភូមិ  ស្នែទៀន  ការនៅទីនេះយូរដែរ  ខ្ញុំបានបំផុសយុវជននៅជាមួយខ្ញុំថា  យើងមិនបាច់ចូលបដិវត្តទេ  បើអង្គការជ្រើសរើសយុវជនភូមិយើងនេះ  យើងត្រូវឱ្យពុកម្តាយយើងរកគ្រួសារឱ្យ  ដូច្នេះការដាច់ចោលឪពុកម្តាយក៏ចៀសផុតទៀត  ហើយសប្បាយ-នៅជុំគ្នា  ។  ពេលដែលខ្ញុំនិយាយនេះយុវជនខ្លះមិនព្រមចូលបដិវត្តទេ  អង្គការត្រូវការរត់មកផ្ទះវិញ  ខ្លះទៀតចូលហើយ  យូរបន្តិចរត់មកផ្ទះវិញ  ។ ក្រោយពីបំផុសនេះហើយ  ខ្ញុំបានធ្វើសកម្មភាពទៅបំផ្លាញស្រូវប្រជាជននៅភូមិស្នែទៀន -ទៅនេះគឺជាមួយ សាន់- ឆុន ដោយខ្ញុំទាក់ទងបបួលគាត់ទៅបំផ្លាញ  ស្រូវនេះទុំហើយ  ខ្ញុំបានលួចដុតឱ្យឆេះអស់ច្រើនដែរ  ។  បន្ទាប់ពីដុតហើយ  ខ្ញុំបំផុសប្រជាជនថា  កងទ័ពលួចដុតស្រូវយើងអស់ហើយ  ពេលនោះប្រជាជនមានការជេរខ្លះពិសេសម្ចាស់ស្រូវគេ  ។

ដល់ឆ្នាំ ១៩៧២និងឆ្នាំ ១៩៧៣នេះ  អង្គការបានដកកម្លាំងពីភូមិរបស់ខ្ញុំនេះទៅដាក់នៅកន្លែងផ្សេងៗទៀត  ពេលនេះអង្គការដកដោយទាំងកម្លាំងរបស់ខ្ញុំទៀត ហើយខ្ញុំត្រូវដាច់ខ្សែទាក់ទងទាំងអស់  ព្រោះគ្មានពីណាទៅណោះ  នៅតែ ប្រ

ជាផលមិនថែមនកម្លាំងរបស់ខ្ញុំ ។

ក្រោយមកទៀតបានប្រហែលជាកន្លះឆ្នាំ អង្គការបានជ្រើសរើសកងទ័ពភូមិ ខ្ញុំឱ្យចូលបំរើទៅសមរភូមិមុខ ដល់ឃើញដូច្នេះម្តាយខ្ញុំបានហៅទៅអប់រំថា អាអែង កុំធ្វើបដិវត្តអី បើគេរើសយកទៅឱ្យធ្វើអាអែងត្រូវរត់មកផ្ទះវិញឱ្យបាន ។ ប៉ុន្តែឥឡូវនេះអាអែងយកប្រពន្ធទៅ បានចៀសវាងដាច់ចោលពុកម្តាយដូច មើល ឪពុកអាអែងគឺគេចាប់យកទៅទៀត ពេលនេះអាអែងមិនបាច់ទៅធ្វើទេយកប្រពន្ធ វិញទៅ ។ ក្រោយពីគាត់ណែនាំនេះបានមួយខែ ម្តាយខ្ញុំបានរៀបចំគ្រួសារឱ្យ ខ្ញុំទៀត ពេលនេះខ្ញុំមិនបានទៅទាក់ទងនកកម្លាំងធ្វើសកម្មភាពឯណាទេ គឺដាច់គ្នា មួយរយៈ ។

ដល់ដើមឆ្នាំ ១៩៧៥នេះ អង្គភាពឃោឃាតំបន់២៥ បានទៀងមកសុំខ្លួនសំ រាកនៅផ្ទះខ្ញុំ ពេលដែលមកសំរាកនេះមានឈ្មោះ សាមុត ជាប្រធានអនុសេនា តូច បានមកទាក់ទងនឹងខ្ញុំ ពេលដល់ដំបូងសាមុតមិនទាន់និយាយអីជាមួយខ្ញុំទេ ទាល់តែ បានប្រហែលកន្លះខែក្រោយមក សាមុតបានហៅខ្ញុំទៅអប់រំថា បងឯងរស់នៅសព្វ- ថ្ងៃលំបាកទេ បើធ្វើស្រែប្រវាស់ដៃ ដើម្បីគ្មានអង្គការវិន័យមិនបាន ហើយរបបសម្ភ ភាពទៀត ពេលនោះខ្ញុំឆ្លើយប្រាប់សាមុតវិញថា ឥឡូវនេះលំបាកដែរ គ្រាន់ តែធ្វើស្រែប្រវាស់ដៃលំបាកបណ្តើងទៅហើយ ចាំរាំទៅមុខទៀតលំបាកយ៉ាងណាទៅ ។ បន្ទាប់មកសាមុត បានពន្យល់ខ្ញុំថា យើងធ្វើបដិវត្តសព្វថ្ងៃនេះគ្មានសិទ្ធិសេរីភាពអីទេ គ្រាន់តែនាមថាធ្វើបដិវត្ត ដូចបងឯងធ្វើជាប្រជាជននៅតែប្រជាជនអញ្ចឹង មិន ដែលបាននាទីដំណែងអីទេ ប្រជាជននៅតែប្រជាជនមួយអាយុស ។ រួចហើយសាមុត

បានសួរខ្ញុំថា ម៉េចសុខចិត្តធ្វើតាមខ្ញុំឬទេ បើធ្វើតាមខ្ញុំមិនអីទេ ទៅអនាគតភ្លឺ - ស្វាងត្រចះត្រចង់ អត់មានទីថ្លៃថ្នូរត្រឹមត្រូវទៀត បើបងឯងមិនចូលមកតាមខ្ញុំ ទេ ប្រយ័ត្នស្តាយក្រោយ តិចមិនបានឃើញអនាគតថ្មីនឹងគេ ។ ដូចបងឯងឃើញស្រាប់ ហើយ អនាគតនេះគ្មានស្រីស្រាលបង្ហាយលេងទេ ធ្វើអីទាល់តែសុំអង្គការវិន័យ ។ ក្រោយពីសាមុតបានអប់រំខ្ញុំហើយ ខ្ញុំឆ្លើយប្រាប់សាមុតវិញថា ខ្ញុំសុខចិត្តចុះចូលបំរើផែន ការនេះដាច់ជានិច្ចរហូត ។ បន្ទាប់ពីខ្ញុំថាសុខចិត្តចុះចូលហើយ សាមុតបានដាក់ ផែនការឱ្យខ្ញុំធ្វើគឺ បងឯងត្រូវខំទាក់ទងកសាងកម្លាំងបង្កប់នៅក្នុងភូមិនេះឱ្យបាន - ច្រើន នឹងយើងជ្រើសរើសកម្លាំងខ្លះសំរាប់ធ្វើជាស្នូលបង្អែករបស់យើង ឥឡូវនេះ បងឯងត្រូវខំកសាងឱ្យបានចុះ បើបានច្រើនរាយការណ៍ប្រាប់ខ្ញុំ ។ មួយទៀតត្រូវ ធ្វើសកម្មភាពបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមប្រវាស់ដៃ ធ្វើម៉េចយើងត្រូវបំផ្លាញ - ឱ្យខិចខិលដាច់ ដើម្បីកុំឱ្យប្រជាជនជឿលើបដិវត្តន៍រៀបចំសហករណ៍ ។ ដល់ប្រ ជាជនគេជឿ យើងមិនងាយសំរេចផែនការទីវបដិវត្តបានទេ ដូច្នេះទាល់តែយើង ធ្វើសកម្មភាពបំផ្លាញឱ្យដាច់ទើបបានសំរេច ។ ក្រៅពីនេះទៀតក៏ត្រូវយក ចិត្ត ទុកដាក់ដែរលើបញ្ហាបំផុសប្រជាជនដែលធ្វើសហករណ៍នេះ បងឯងបំផ្លាញទ្រព្យ សហករណ៍ហើយ យើងត្រូវបំផុសថា ធ្វើសហករណ៍មិនរីកចំរើនទេ ទាល់តែខ្លាំង បំ ផ្លាញអស់ បើនៅឯកជនវិញស្រួល នេះដើម្បីបំភាន់ប្រជាជន ។ ក្រោយ ពីសាមុតអប់រំខ្ញុំបានហើយ សាមុតបានឱទេសនាមកម្លាំងខាងលើពុកនៅក្នុងយោធាតំបន់ - ២៥ឱ្យខ្ញុំស្គាល់មានឈ្មោះ :

១ - ភិន មុនអង្គការចាប់ប្រធានអនុសេនាធំ យោធាតំបន់២៥ ។

២- ខុម  មុនអង្គការចាប់ ជាសមាជិកកងអនុសេនាធំ នៅយោធាតំបន់
២៥ ។

៣- សាមគ្គី មុនអង្គការចាប់ អនុប្រធាន អនុសេនាធំ នៅយោធាតំបន់២៥

៤- សាវុធ មុនអង្គការចាប់ ប្រធានអនុសេនាធំ នៅយោធាតំបន់២៥ ។

ក្រៅពីនេះទៀត ដូចមានបងឃុំ- បងយូក- ធុន ទាំងអស់នេះគាត់ធ្លាប់នៅក្នុង តំបន់២៥យើងទាំងមូល មិនអីទេត្រូវតែធ្វើចុះ ពីព្រោះឥឡូវនេះយើងមានបង្ហែ ករឹងខ្លះហើយ ។ រៀបរ័បកន្លាចេញហើយ សាធុមបានប្រាប់ខ្ញុំថា នេះជាមេ ដឹកនាំរបស់យើងក្នុងការប្រឆាំងបដិវត្តលួចថ្ងៃនេះ យើងសំរេចទៅតាមសំណូមពរ នេះបាន បងរឹងឯចំកសាងកម្លាំងបង្កប់នៅក្នុងភូមិនេះឱ្យបានច្រើនទៅ ហើយកសាង គេឱ្យបង្កប់ឱ្យបានយូរអង្វែង ដើម្បីធ្វើសកម្មភាពបំផ្លិចបំផ្លាញ និងរៀបចំផែនការ ថ្មីទៀត ។ ក្រោយពីទទួលផែនការនេះហើយ ខ្ញុំបានចុះទៅអនុវត្ត ។ ខ្ញុំសូមបញ្ជាក់អំពីកម្លាំងចាស់របស់ខ្ញុំនៅពេលនោះ អង្គការបានបោសសំអាតខ្លះ ខ្លះ អង្គការមិនឱ្យនៅភូមិនឹង ដកចេញទៅនៅភូមិផ្សេងទៀត ដូច្នេះខ្ញុំមិនបានទាក់ ទងទេ ដល់ឆ្នាំ ១៩៧៤ ខ្ញុំដាច់ជាមួយយោធាតំបន់២៥ ព្រោះពេលនេះយោធា- មកនៅផ្ទះខ្ញុំ ។ ក្រោយពីនេះមកទៀត ខ្ញុំបានកសាងកម្លាំងបាន ១នាក់ឈ្មោះ

១- ឆ្នាំង   អតីតៈធ្វើស្រែ បច្ចុប្បន្នធ្វើទ័ពយោធាតំបន់២៥ ឥឡូវនេះពិ
ការនៅក្រសួងពិការតំបន់២៥ ។

គាត់នេះធ្លាប់ជិតស្និទ្ធជាមួយខ្ញុំ ហើយនឹងមានមនោសញ្ចេតនាមកលើរូបខ្ញុំ ដល់ខ្ញុំណែនាំ នឹងអូសទាញទៅ គាត់ក៏សុខចិត្តដើរ នឹងធ្វើសកម្មភាពតាមខ្ញុំ ។ បន្ទាប់ពី

កសាងបានហើយ ខ្ញុំបានទៅរាយការណ៍ប្រាប់ឈ្មោះ សាមុតឱ្យដឹងអំពីកម្លាំងដែលខ្ញុំកសាងបាន ៗ ក្រោយពីរាយការណ៍ឱ្យហើយ ខ្ញុំបានបែកចេញពីសាមុតទៅ ៗ បន្ទាប់មកទៀតខ្ញុំបានបបួលឈ្មោះ ឆ្នាំង ដែលកម្លាំងខ្ញុំកសាងបានទៅធ្វើសកម្មភាពបំផុសនៅក្នុងសហករណ៍ ពេលនោះនៅជាសហករណ៍ប្រវាស់ដៃទេ ភូមិរបស់ខ្ញុំ ខ្ញុំបានបំ-ពីរឿងនៅសមូហភាព នឹងរស់នៅឯកជន ខ្ញុំបានលើកឡើងថា រស់នៅសមូហភាពលំបាកណាស់ ធ្វើការមានពេលម៉ោងធ្វើ ដើរទៅណាមកណាទាល់តែមានអង្គការឱន័យ ទើបដើរបាន បើមិនអញ្ចឹងទេ គេចោទថាយើងជាខ្មួយក៏បានដែរ ៗ បើឱ្យយើងរស់នៅឯកជនវិញ ធ្វើអីបានតាមចិត្តមិនអ្នកណាមកផ្សើអីទេ ចង់ដើរទៅណាក៏បាន សប្បាយទៀត ៗ ក្រោយពីខ្ញុំ- ឆ្នាំង បំផុសរឿងនេះមកប្រជាជនក្នុងក្រុមប្រវាស់ដៃរបស់ខ្ញុំ អ្នកខ្លះក៏មកធ្វើការ ខ្លះនៅធ្វើការឯកជនរបស់ខ្លួន រហូតទៅជាទំនាស់គ្នាប្រប៉ូកប្រចប់ថែមទៀត ៗ ដោយមកពីអ្នកខ្លះធ្វើការ អ្នកខ្លះមិនទៅធ្វើការ ដូច្នេះវាទំនាស់គ្នា ៗ

នៅពាក់កណ្ដាលខែ ៧ ឆ្នាំ ១៩៧៥នេះ ខ្ញុំ- ឆ្នាំង បានបំផ្លាញស្រូវរបស់-ក្រុមប្រវាស់ដៃ ដែលតើមខ្លះ ខ្លះបែកហើយ ពេលនោះខ្ញុំជាមួយ ឆ្នាំងបានដើរបើកទឹកចេញអស់ពីស្រែ បានប្រហែល១០ថ្ងៃ បានឃ្លាលទៅមើល ដូច្នេះស្រូវ ខូចអស់ ៥ហិកតា ប្រើការមិនកើត ៗ បន្ទាប់ពីខ្ញុំបានបំផ្លាញនេះមក សាមុត ប្អូនហៅខ្ញុំ- ឆ្នាំង ទៅណែនាំ ពេលទៅដល់សាមុតមិនទាន់ណែនាំទេ បានសួរខ្ញុំថាម៉េចផែនការពីពេលមុននោះអនុវត្តបានប៉ុន្មានហើយ ខ្ញុំបានឆ្លើយប្រាប់គាត់វិញថាខ្ញុំកសាងកម្លាំងបានតែម្នាក់ទេ ដូចបានរាយការណ៍ឱ្យពីមុនអញ្ចឹង ៗ បន្ទាប់មកទៀតបានបំ

ផ្លាញស្រូវរបស់ក្រុមប្រវាស់ដែរច្រើនដែរ ។ និងបំផុសនៅក្នុងសហករណ៍ឱ្យច្របូក
ច្របល់ទៀត ។ ក្រោយពីរាយការណ៍ហើយ សាមុតបានអប់រំពន្យល់ខ្ញុំថា បដិវត្ត-
យើងធ្វើមិនបានដើយជំនះទេ បងឯងកុំទៅតាមវាគី មិនបានសុខស្រួលទេ ដូចខ្ញុំ ថា
វាប្រផុលទៅហើយ ហេតុដូច្នេះបុងឯងដែលមិនទាន់នៅក្នុងជួរបដិវត្តទេ មិនបាច់ចូល
ទេ ។ ពេលឥឡូវនេះយើងបំរើបក្សមួយទៀត បងឯងត្រូវស្រឡាញ់បក្ស-
វៀតណាម ព្រោះគេជួយស្រោចស្រង់យើងតាំងពីយូរណាស់មកហើយ ពេលនេះត្រូវ
តែអនុវត្តតាមគេ ។ ហើយទិសវិវត្តរបស់បក្សវៀតណាមនេះ នឹងទៅរកសេច
ក្តីសប្បាយ និងមានអនាគតភ្លឺស្វាងទៀត ។ បើទិសវិវត្តរបស់បដិវត្តកម្ពុជាវិញ-
មានទុក្ខមួយជីវិត នៅតែមិនបានសប្បាយទេ នឹងទៅឱ្យប្រជាជនបះបោរប្រឆាំង
វិញ ។ ដើម្បីសំរេចផែនការសប្បាយទៅអនាគតទៀត បងឯងត្រូវរកវិធីក
សាងកម្លាំងឱ្យបានច្រើន យើងបំរើផែនការនេះនៅពេលខាងមុខ ។ រួចហើយ-
សាមុតបានប្រាប់ខ្ញុំ- និងភ្នាំងថា ឥឡូវនេះខ្ញុំមិនបាននៅទីនេះជាប់ទេ ខ្ញុំត្រូវអង្គ
ការចាត់តាំងឱ្យចេញទៅសមរភូមិទៀត ពេលនេះបងឯងទាំងពីរនាក់ខំកសាងក
ម្លាំងទៀត ។ ម្យ៉ាងទៀតត្រូវតែខំពង្រឹងប្រើលសហករណ៍របស់យើងនេះកុំឱ្យរីក
បំរើនរី ដើម្បីឱ្យសហករណ៍ច្របូកច្របល់ ស្រួលដល់ពេលយើងកសាងកម្លាំងបង្កប់ ។
ក្រោយពីសាមុតបានណែនាំហើយ ក៏បែកគ្នាទៅ ឯសាមុតពេលព្រឹកឡើងឃើញ-
ចេញដំណើរទៅសមរភូមិបាត់ ឯខ្ញុំនៅតែជាមួយភ្នាំង ក្រៅពីនេះទៀតអត់ ។

ដល់ដើមឆ្នាំ ១៩៧៥នេះ ខ្ញុំ- ភ្នាំង បានទៅបំផ្លាញស្រូវជស្រូករបស់សហករណ៍
ក្នុងភូមិរបស់ខ្ញុំ ដែលគេធ្វើដាក់រួមហើយ ពេលនោះខ្ញុំបានទៅចំណាយ ឱ្យឆ្លាយហួរ

អស់ច្រើន ។ បន្ទាប់ពីនេះទៀតនៅក្រោយខ្ញុំបានកាប់អស់ ៥ក្បាល នៅក្នុង-សហករណ៍របស់ខ្ញុំ ។

ផល់ក្រោយរំដោះទូទាំងប្រទេសភ្លាម អង្គការជំលៀសប្រជាជនចេញពីទីក្រុង ទៅនៅក្នុងស្រុករបស់ខ្ញុំ ពេលនោះខ្ញុំ- ឆ្នាំង បានបំផុសប្រជាជនថ្មីនោះ-ថា អ្នកណាមកនៅដីរំដោះនេះ ច្បាស់ជាអង្គការចាប់ទីរំចោលអស់ ឱ្យតែមិនរត់ចេញពីទីនេះ ។ ក្រោយពីខ្ញុំបំផុសមក ប្រជាជនថ្មីភ័យព្រួយខ្លាចអង្គការចាប់ទីរំចោល ខ្លះទៀតរត់ចេញពីស្រុកមួយទៅស្រុកមួយទៀត ដូច្នេះនៅក្នុងសហករណ៍របស់ខ្ញុំ ប្រចូកប្រចល់តែរវើងវត់ និងខ្ញុំធ្វើលកម្មភាពបំផ្លាញសំភារៈរបស់-សហករណ៍ ។ ក្រោយមកនៅក្នុងឆ្នាំ ១៩៧៥ដែលមានឈ្មោះ អោក អនុសង្កាត់ ទឹមលេខាសង្កាត់រាក់ជ័យ គាត់ទាំងពីរនាក់នេះបានមកអប់រំខ្ញុំជាមួយនឹងឆ្នាំង នៅកន្លែងភ្នូរដីរាល់ស្តូង គាត់បានមកនិយាយលេងជាមួយខ្ញុំ- ឆ្នាំងថា គាត់និយាយលើក ពីនេះពីនោះ បន្ទាប់ពីគាត់និយាយស្ទាប់ស្ទង់ខ្ញុំស្រួលហើយ គាត់បាននិយាយអប់រំខ្ញុំត្រង់-ថា ម៉េចមិត្តទាំងពីរនាក់សុខចិត្តដើរតាមខ្ញុំទេ ពេលនោះខ្ញុំសួរគាត់វិញថា : ឲ្យខ្ញុំដើរតាមអី បើខ្ញុំមិនទាន់ដឹងផង គាត់ថាឱ្យតែថាដើរតាម គេប្រាប់ឱ្យដឹង ឱ្យតែព្រាប់ខ្ញុំគោរពនឹងដើរតាមទាំងអស់ ។ រួចហើយគាត់និយាយថាឥឡូវនេះមិត្តទាំងពីរនឹងដើរតាមខ្ញុំទៅ អនាគតភ្លឺស្វាងណាស់ សម័យនេះមិត្តឃើញហើយបដិវត្តសប្បាយទេ អង្គការប្រកាសថាបដិវត្តសប្បាយហូរហារ តាមការពិតគ្មាន-ត្រូវត្រង់ណាបន្តិចទេ ដូចមិត្តឃើញស្រាប់ ពេលរំដោះឱ្យតែអ្នកណាហ៊ានជីកស៊ី អីបន្តិចប្រកាន់ ត្រឹមតែមិនប្រកាន់ យកទៅបាញ់ចោល ។ មួយទៀតទៅណា-

មកណាទាល់តែសុំ ទើបទៅបាន ដូច្នេះអ្នកណាថា បដិវត្តមានសិទ្ធិសេរីភាពមិនមែនទេ គ្រាន់ថាបដិវត្តប៉ុណ្ណឹង ៗ រួចហើយពូទីម បានសួរខ្ញុំ- ធ្នាំងថា ម៉េចសុខ ចិត្តធ្វើតាមខ្ញុំឬទេ បើធ្វើអនាគតត្រចះត្រចង់ណាស់ រស់នៅមានស្រីស្រាតាមតែចិត្តចង់ ៗ យ៉ាងទៀតនៅឯកជនស្រួលទៀត មិនបិទសិទ្ធិសេរីភាពដូចនេះទេ ៗ បន្ទាប់មកខ្ញុំបានប្រាប់គាត់វិញថា ខ្ញុំពីដើមក៏ដូចពេលនេះដែរ ខ្ញុំធ្លាប់ធ្វើសកម្មភាពបំរើផែនការនេះហើយ ទើបតែដាច់ខ្សែទាក់ទងពេលមុនពុនេះទេ ព្រោះអង្គការចាប់ខ្លះ ខ្លះទៀតបែកគ្នាទៅឃោឃាក៏មានដែរ ៗ ហើយបងទីមបាន ណែនាំខ្ញុំថា មិត្តឯងទាំងអស់នេះត្រូវយកចិត្តទុកដាក់កសាងកម្លាំងឱ្យបានច្រើនផែនការឃើងនៅក្នុងឆ្នាំ ១៩៧៥នេះ ឃើងបង់ទាមទារកម្លាំងនៅគ្រប់ភូមិឱ្យបានច្រើន - មួយទៀតជាកន្លិះសំខាន់ដែរ ត្រូវពង្រីកពង្រីលកម្លាំងបដិវត្ត ផាពិសេសនៅ ក្នុងសហករណ៍ឃើងនេះ ធ្វើសកម្មភាពបំផ្លាញឱ្យបានដាច់ ឱ្យសហករណ៍នឹងវិចវិលទៅ ពុដល់ទីបំណាមួយរបបឃើងទៀងមកកាន់កាប់រដ្ឋអំណាចបដិវត្តមិនខាន ដូច្នេះមិត្តខិតខំបំផ្លាញទៅ ៗ បើសហករណ៍ចាត់តាំងឱ្យធ្វើអី ត្រូវបំផ្លាញរបស់នឹង ៗក្រោយពីគាត់អប់រំខ្ញុំហើយ ពូទីមបានឱ្រទេសនាយកម្លាំងឱ្យខ្ញុំទាក់ទងគ្នាធ្វើសកម្មភាពមាន :-

១- អោក អតីតៈធ្វើស្រែ បច្ចុប្បន្នអនុសង្កាត់រាក់ជីង ស្រុកបាភ្នំ តំបន់ ២៤ ៗ

២- ស្លឹក អតីតៈធ្វើស្រែ បច្ចុប្បន្ននៅសហករណ៍ភូមិតាពេជ ឃុំរាក់ជីង ស្រុកបាភ្នំ តំបន់ ២៤ ៗ

៣- ចែត អតីតៈធ្វើស្រែ នៅវិប្បធម៌ឃុំរាក់ជីង បច្ចុប្បន្នអង្គការចាប់

ក្រោយពីឱទទួលនាមឱ្យស្គាល់ហើយ គាត់បានប្រាប់ខ្ញុំថា កម្លាំងដែលខ្ញុំឱទទួលនាមឱ្យស្គាល់នេះ ទាក់ទងគ្នាធ្វើសកម្មភាពចុះមិនអីទេ ព្រោះកម្លាំងនេះខ្ញុំកសាងបានមកយូរហើយ រួចហើយក៏បែកគ្នាទៅ ។ ក្រោយពីបានទទួលផែនការនេះមក ខ្ញុំបានយកទៅអនុវត្តជាមួយឆ្នាំង ប៉ុន្តែខ្ញុំមិនទាន់បានចុះទៅធ្វើសកម្មភាពភ្លាមទេ បាននាំគ្នាទៅទាក់ទងនឹងកម្លាំងបងថឹមឱទទួលនាមឱ្យស្គាល់សិន ។ ហើយក៏បាននាំឆ្នាំង ទៅទាក់ទងបងទាំងអស់នោះ ពេលទៅដល់ផ្ទះគាត់ទាំងអស់មិនទៅណាទេ ហើយខ្ញុំបាននិយាយប្រាប់គាត់ត្រង់ថា បងនៅនេះឬមានបងថឹមបានប្រាប់បងយ៉ាងម៉េចទេ ពេលនោះបងអោកឆ្លើយប្រាប់ហើយខ្ញុំទាំងពីរនាក់ថា ខ្ញុំនៅទីនេះមិនទាន់ដឹងទេតាំងពីនោះមកមិនទាន់ឃើញមកម្ដងផង ហើយខ្ញុំបានឆ្លើយប្រាប់គាត់វិញថា បងថឹមថាឱ្យខ្ញុំទាំងពីរនាក់នេះមករួមកម្លាំងជាមួយបងធ្វើសកម្មភាព ។ បន្ទាប់ពីបាននិយាយប្រាប់គាត់ដូច្នេះមក បងអោក- ស្លឹក- ផែត ក៏ទទួលស្គាល់ខ្ញុំជាកម្លាំងសំរាប់ទាក់ទងគ្នា ៗ ហើយក៏បែកគ្នាទៅ ។ ខ្ញុំ- ឆ្នាំង បានត្រឡប់មកផ្ទះវិញ ពេលមកដល់ផ្ទះវិញខ្ញុំឆ្នាំង បានធ្វើសកម្មភាពបំផ្លាញស្រូវរបស់សហករណ៍ គឺស្រូវដែលទើបស្ទូងពួកខ្ញុំបានដើរបំផ្លិចបំផ្លាញដោយលួចបើកទឹកឱ្យហូរចោលអស់ ដើម្បីឱ្យស្រូវនោះស្លកឬងាប់ ។ បន្ទាប់មកទៀតអំពីបញ្ហាមួយទៀត ខ្ញុំនឹងពួកខ្ញុំបានយកចិត្តទុកដាក់ធ្វើផែនការ បំបែកបំបាក់កម្លាំងសមូហភាព ឱ្យវាក្លាយទៅជាកម្មសិទ្ធឯកជនវិញ តាំងពីក្រោយណែនាំនឹងដាក់ផែនការមក ខ្ញុំនឹងបក្សពួកយកចិត្តទុកដាក់ធ្វើសកម្មភាព នឹងបំបែកបំបាក់អ្នកបដិវត្តជាប់ ដើម្បីពួកខ្ញុំងាយកសាងមកជាកម្លាំង ។ ក្រៅពីនេះទៀត ការរស់នៅខ្ញុំបានបំផុសឱ្យប្រជាជនរស់នៅមិនបដិវត្ត គឺបំផុសឱ្យប្រជាជនមានទំនាស់នឹង

សហករណ៍របស់បក្សបញ្ចូថ្មីនេះ ។

ដល់ចុងឆ្នាំ ១៩៧៥នេះ ខ្ញុំក៏នៅអនុវត្តបញ្ហានេះទៀតដែរ បងទឹម បងអោក- ស្លឹក- រ៉ុត បាននិយាយពិភាក្សាគ្នាថា រឿងនេះត្រូវតែធ្វើតទៅទៀតរឿងនេះ កន្លងមកវាបានខ្លះហើយ ពេលនេះត្រូវតែខំបន្តទៀតឱ្យវាបានឆាប់ឆ្លងការរៀបចំសង្គមថ្មី ។ មួយទៀតបងទឹមបានឱ្យបក្សពួកទាំងអនុវត្តគឺ សតិអារម្មណ៍ត្រូវបំផុសយុវជន- យុវនារីឱ្យមានសីលធម៌ឡើងវិញ ដើម្បីកុំឱ្យអង្គការដោះ - បានរួចពីសភាពការណ៍នេះ ។ នៅក្នុងឆ្នាំនេះខ្ញុំកសាងកម្លាំងមិនបានទេ ។ ដល់ដើមឆ្នាំ ១៩៧៦ បងទឹមបានហៅខ្ញុំ- ឆ្នាំង- ផែត- ស្លឹក- បងអោក ទៅណែនាំនៅមន្ទីរសង្កាត់ ពេលនោះគាត់បានលើកកំណត់ផែនការថា នៅក្នុងឆ្នាំ១៩៧៦នេះត្រូវធ្វើសកម្មភាពឱ្យបានខ្លាំងក្លា នៅតាមមូលដ្ឋានសហករណ៍យើងនេះ ហើយនឹងឆ្លងទៅទាក់ទងកន្លែងផ្សេងទៀត ដើម្បីរាវរកខ្សែទាក់ទងឱ្យបានច្រើនទៀត ហើយការធ្វើសកម្មភាពយើងក៏ធ្វើតែនៅក្នុងសហករណ៍យើងនេះ ក្រៅពីនេះ ក៏យើងធ្វើដែរ ធ្វើម៉េចឱ្យតែបដិវត្តវិចវិល នេះបានងាយស្រួលដល់រៀបចំផែនការ ។ បន្ទាប់បងទឹមបានបន្តទៀត បញ្ហាទាក់ទងគឺយើងត្រូវតែធ្វើម៉េចកុំតែទាក់ទងនៅកន្លែងយើងនេះពេក ក្រៅពីនេះទៀតក៏យើងអាចទាក់ទងបាន នេះដើម្បី មចផ្តុំកម្លាំងឱ្យបានច្រើន ។ ម្យ៉ាងទៀតបញ្ហាកសាងកម្លាំងគឺថា យើងទាំងអស់គ្នាខំអនុវត្តកសាងកម្លាំងឱ្យបានក្នុងឆ្នាំនេះធ្វើម៉េចក្នុងម្នាក់ឱ្យបានពី ៥.៧នាក់ដែរ ក្នុងមួយឆ្នាំនេះ ដើម្បីឱ្យកម្លាំងនេះជាច្រើនស្លេកស្លះឡើងទៅ ។ ដូចនេះកម្លាំងកសាងហើយ ត្រូវយកចិត្តទុកដាក់បង្កប់ស៊ីរូងឱ្យបានយូរអង្វែង ។ ដូច្នេះត្រូវអនុវត្ត

ឱយបានដាច់លាច់ក្នុងផែនការនេះ ៗ មួយទៀតនៅក្នុងសហករណ៍យើងនេះ ត្រូវបំផុសបញ្ហាសីលធម៌ ស.មមិត្តយើងធ្វើរឿងនេះឆាប់ណាស់ ខ្លះគេមានប៉ះពាល់យើងអួលទាញទៅបានធូរ ដោយបំភ័យឱយគេខ្លាចអង្គការចាប់ ម្លោះហើយងាយធ្វើបានទេ ត្រូវយកចិត្តទុកដាក់ថែមទៀត ៗ រួចហើយបងទឹម បានលើកសភាពការណ៍កន្លងមកថា ពេលនេះសភាពការណ៍នៅក្នុងតំបន់របស់យើងបានស្រួលបន្តិចហើយ ដោយកម្លាំងយើងនេះបានលក្ខការណ៍ ៗ អង្គការចាប់ផែរ គឺចាប់តែអ្នកមេពួងណោះ-ទេ គឺកម្លាំងតូចៗអង្គការមើលមិនឃើញទេ ដូច្នេះយើងអាចពង្រីកបានទៀតកាន់តែច្រើន ហើយស.មមិត្តទាំងអស់ត្រូវខិតខំយកចិត្តទុកដាក់ចុះមិនអីទេ បើយើង ប្រហែលវាបាត់អស់ហើយ កម្លាំងយើងក៏ខ្ទេច ដោយអង្គការចាប់ ៗ បន្ទាប់ពីប្រជុំមក បងទឹមបានលើកផែនការឱយអនុវត្ត :

១– ត្រូវយកចិត្តទុកដាក់កសាងកម្លាំងឱយបានច្រើន និងរក្សាកម្លាំងចាស់ឱយបាន ហើយកសាងកម្លាំងថ្មីបង្កប់ឱយបានគ្រប់ភូមិ នៅក្នុងសង្កាត់យើងនេះ ៗ

២– ត្រូវយកចិត្តទុកដាក់ផែរធ្វើសកម្មភាពបំផ្លាញទ្រព្យរបស់សហករណ៍និងបំផុសចំនោលឱយកាន់តែខ្លាំងទៀត ៗ

៣– បញ្ហានេះគឺយើងម្នាក់ៗត្រូវបំផុសរឿងសីលធម៌ និងរស់នៅក្នុងរបបសព្វថ្ងៃនេះគឺរបបបដិវត្ត ឱយគេប្រឆាំងនឹងរបបនេះ ៗ

ក្រោយពីលើកផែនការនេះមក បងទឹមបានសួរយោបល់អង្គប្រជុំថា តើបស.ម មិត្តចង់បន្ថែមផែនការអីទេ ពេលនោះអង្គប្រជុំមានយល់ស្របទៅតាមមតិរបស់បង ទឹម ហើយក៏បែកគ្នាទៅបំពេញភារៈកិច្ចរៀងៗខ្លួនតាមមុខសញ្ញារបស់ខ្លួនធ្វើ ៗ ខ្ញុំពីរ

ឆ្នាំងបានផ្ទះរបស់ខ្លួនវិញ ។ ពេលនេះខ្ញុំបានរួមគ្នាដើរបំផុសបំផុលចលនារបស់សហករណ៍ដែលគេកំពុងទៅមុខ ខ្ញុំបានទៅបន្តបង្ហាក់ ធ្វើមេចបំភ្លៃមាគ៌ារបស់បក្ស បក្សលើកធ្វើស្រែឱ្យបាន៣តោនក្នុងមួយហិកតា ខ្ញុំលើកបំផុសប្រជាជនថា អង្គការឱ្យធ្វើស្រែក្នុងមួយហិកតាឱ្យបាន១តោន បើយើងធ្វើឱ្យបាន៣តោន ទាល់តែនាំគ្នាកប់ខ្លួនធ្វើដីវិញទើបបាន៣តោន នេះខ្ញុំបំផុសម្យ៉ាងទៅ ។ ម្យ៉ាងទៀតបញ្ហា ស៊ីសមូហភាព ប្រជាជនជាទូទៅឯកភាពគ្នាហើយ ប៉ុន្តែខ្ញុំនៅបំភ្លៃមាគ៌ានេះធ្វើឱ្យប្រជាជនមានទំនាស់គ្នាច្របូកច្របល់ក្នុងសហករណ៍ ។

ក្រោយមកទៀតខ្ញុំបានទៅទាក់ទងស្លឹក - ឆ្នាំ - [illegible] ទៅធ្វើសកម្មភាពបផ្លិចបំផ្លាញស្រូវរបស់សហករណ៍ ព្រោះខ្ញុំទៅម្នាក់ឯងមិនហ៊ានទៅ បើទៅនៅ ពេលម៉ោង៥.៦ពេលល្ងាច ដើម្បីកុំឱ្យគេឃើញ ម្លោះហើយបានប្រមូលគ្នាទៅ ពួកខ្ញុំបានទៅកាប់ចំលាយភ្លឺស្រែអស់ប្រហែលជា ៤ហិកតាប៉ុណ្ណោះ ព្រោះកន្លែងនឹងមានទំនប់តូចមួយ ហើយពួកខ្ញុំបានទៅលួចកាប់ចំលាយទៅ ។ ហើយបាននាំគ្នាត្រឡប់មកវិញ

ក្រោយមកទៀតខ្ញុំបានកសាងឈ្មោះ :

១- យូន បច្ចុប្បន្នប្រជាជននៅសហករណ៍តាពេជខាងជើង ឃុំរាក់ជ័យស្រុកបាភ្នំ តំបន់២៤ ។

២- ម៉ង់ បច្ចុប្បន្នទៅនៅមន្ទីរឃុំរាក់ជ័យ ស្រុកបាភ្នំ តំបន់២៤ ។

៣- ថន បច្ចុប្បន្ននៅយុវជនកងចល័តឃុំរាក់ជ័យ ស្រុកបាភ្នំ តំបន់២៤ ។

ឈ្មោះដែលអប់រំបាន គឺខ្ញុំ- ឆ្នាំង ជាអ្នកអប់រំផ្ទាល់ ដំបូងអ្នកទាំងអស់នេះ ក្រោយពីខ្ញុំបំផុសទំនាស់ នឹងធ្វើសកម្មភាពបំផុសរឿងសីលធម៌នេះមក គាត់ទាំងអស់នេះមាន

ស្មុគស្មាញ ហើយដើរអបរកតែអ្នកក្បត់ ដល់មកប៉ះខ្ញុំ- ឆ្នាំងក៏ចាប់អប់រំគាត់ នឹងពន្យល់អំពីបដិវត្តយួន ខ្ញុំលើកថា មិត្តមើលបដិវត្តយួនសព្វថ្ងៃនេះឮថាសប្បាយបំរើម ។ ឯបដិវត្តកម្ពុជាវិញឮថាល្អ ដូចេះគ្មានសិទ្ធិសេរីភាពអីទេ ហើយមិត្តដើរតាមខ្ញុំមកអនាគតជីវិតតែត្រចះត្រចង់ទៀត ។ ឥឡូវនេះយើងត្រូវជួយបង្អិចបំផ្លាញទ្រព្យសម្បត្តិរបស់សហករណ៍ ។ និងជួយកសាងកម្លាំងបក្សពួកយើង ដើម្បីវាយកំទេចរបបសមូហភាពលំហុកនេះចេញ ។ ការអប់រំគាត់តាំងពីនាក់នេះ ក៏សុខចិត្តនឹងដើ រតាមខ្ញុំ ហើយខ្ញុំបានឱ្យគាត់ធ្វើសកម្មភាព និងចំកសាងកម្លាំង រួចហើយក៏បែកគ្នាមកកន្លែងរៀងៗខ្លួន ។

ដល់ខែ ៨ ឆ្នាំ ១៩៧៦នេះ បងទឹមបានហៅខ្ញុំទៅប្រជុំនៅមន្ទីរឃុំពេលខ្ញុំទៅដល់មានឃើញអ្នកចូលរួមប្រជុំនោះមានឈ្មោះ ឆ្នាំង- ចែត- ស្លឹក- អោក- និងរូបខ្ញុំផ្ទាល់ ។ ហើយបងទឹមជាប្រធានអង្គប្រជុំ ពេលនោះគាត់លើកឡើងថាឥឡូវនេះសុំស្នើស.មមិត្តតាមកន្លែងនិមួយៗរាយការណ៍អំពីកម្លាំងដែលកសាងបាន ដើម្បីមានទិសទៅមុខទៀត ។ ក្រោយពីលើកអញ្ជើងហើយ ខ្ញុំបានរាយការណ៍ជូនអង្គប្រជុំថាបញ្ហាខ្ញុំ- ឆ្នាំង តាំងពីផែនការលើកមុនមក ហើយដល់ឥឡូវនេះបានកសាងកម្លាំង៣នាក់គឺឈ្មោះ ថន- ម៉ង់- យួន និងបានធ្វើសកម្មភាព និងបំផុសចលនានៅក្នុងប្រ ជាជនទៀត ។ ចែត បានរាយការណ៍ថាកន្លងមកនេះខ្ញុំកសាងកម្លាំងបានម្នាក់ឈ្មោះ -ធឿង និងបានបំផ្លាញស្រូវសន្ទូងអស់ ៥ហិកតា ។ ក្រៅពីនេះមកទៀតបានកាប់ជើងគោរបស់សហករណ៍អស់ ៣ក្បាលទៀត ។ ស្លឹក បានរាយការណ៍ប្រាប់ទៀត ខ្ញុំមិនបានកសាងកម្លាំងទេ ដោយកសាងមិនបាន តែដោយខ្សែកពីនេះទៀតបញ្ហា-

ធ្វើសកម្មភាព ខ្ញុំបានយកចិត្តទុកដាក់ធ្វើហើយ នៅកសាងកម្លាំងមិនទាន់បាន ។ ដល់ពេលរាយការណ៍សព្វគ្រប់ហើយ បងទឹមបានណែនាំលើកបំភ្លឺពួកយើងខ្ញុំទៀតថា បញ្ហាកសាងកម្លាំងក៏ដូចការធ្វើសកម្មភាពដែរ គឺថាយើងមិនទាន់បានលកម្មប្រយុទ្ធពុះពា រការលំបាកស្រួលរបស់យើងទេ ដូច្នេះបញ្ហាដែលនាំឲ្យយើងកសាងកម្លាំងមិនបានគឺមកពីយើងមិនសូវយកចិត្តទុកដាក់ ព្រោះនៅខ្លាច ។ រួចហើយបងទឹមបានបញ្ជាក់ អំពីផែនការ មិត្តយើងទាំងអស់ត្រូវតែធ្វើតទៅទៀត យើងអនុវត្តឲ្យបានសំរេចតាមទិសដៅដែលខ្ញុំដាក់នេះ ។ ដូច្នេះផែនការមិនមានអ្វីផ្លែកទេ ហើយមិត្តយើងអនុវត្តទៀតចុះ ហើយត្រូវលកម្មប្រយុទ្ធបំពេញឲ្យបានជាប់ជានិច្ច ។ ក្រោយពីបងទឹមមានយោបល់ចប់មក គាត់ក៏បិទអង្គប្រជុំ ។ ក្រោយពីបិទអង្គប្រជុំ ខ្ញុំបានដើរមកផ្ទះវិញ ។ ក្រោយពីប្រជុំនេះបានបន្តានថ្ងៃអង្គការចាប់ឈ្មោះ ស្លឹក-ថែត-ទឹមបាត់ទៅ ដល់ឃើញសភាពដូចនេះខ្ញុំមិនហ៊ានធ្វើសកម្មភាពទេ ដោយខ្លាចអង្គកា រនឹងដល់រូបខ្ញុំ ត្រូវផ្អាកសកម្មភាពមួយរយៈ ។ ប្រហែលជាចុងឆ្នាំ ១៩៧៦ក្រោយដែលឃើញកម្លាំងមិនធ្វើសកម្មភាព បងអោកបានហៅកម្លាំងទៅណែនាំទៀត បងអោកគាត់ជាអនុសង្កាត់ ក្រោមបងទឹម ដល់បងទឹមចាប់ទៅ បងអោកគាត់ទទួលសង្កាត់ ។ ក្នុងអង្គប្រជុំនោះមានឈ្មោះ ឆ្នាំង- ខ្ញុំ- នឹងឃើញកម្លាំងរបស់អោកពីរនាក់ទៀតឈ្មោះ ចយ- សារិន បងអោកលើកឡើងថា ឥឡូវនេះស.ម មិត្តឃើញស្រាប់ហើយ គ្រាន់តែក្រោយពីប្រជុំភ្លាម អង្គការចាប់កម្លាំងយើងភ្លាម ៗ ដូចនេះបើអស់មេដឹកនាំអញ្ចឹងទៅ តើយើងទៅមានផែនការអីណា យើងមិនដឹងខ្សែខាងក្រៅដូចគាត់ ហេតុនេះស.មមិត្តត្រូវធ្វើសកម្មភាពដោយប្រុងប្រយ័ត្នស្ងាត់

បំផុត ធ្វើមេចកុំឲ្យអង្គការដឹង ។ ប៉ុន្តែត្រូវបន្តទៀត ដោយធ្វើល្វាស់បំផុតនឹងលក្ខការណ៍ឲ្យជិត ។ រួចហើយបងអោកបានឧទ្ទេសនាមកម្លាំងថ្មីរបស់គាត់ឲ្យខ្ញុំ- ម្នាង ទាក់ទងរួមគ្នាធ្វើសកម្មភាព មានឈ្មោះ ចយ- សារិន រួចហើយក៏បែកគ្នាទៅ ។ ខ្ញុំបានត្រឡប់មកផ្ទះវិញដែរជាមួយនឹង ម្នាង ។

ដល់ដើមឆ្នាំ ១៩៧៧នេះ យោធារបស់តំបន់ ២៥ បានមកនៅជិតសហករណ៍របស់ខ្ញុំ ជាដំបូងខ្ញុំមិនទាន់បានស្គាល់ម្នាក់ណាមួយទេ ។ ដល់ប្រហែលកន្លះខែក្រោយ- មក ទើបឃើញសាមុតដែលជាខ្សែរបស់ខ្ញុំចាស់ពីដើម គាត់បានមកទាក់ទងជាមួយខ្ញុំទៀត សាមុតបានមកសួរខ្ញុំថា មេចផែនការធ្វើ នឹងកសាងកម្លាំងតាំងពីក្រោយខ្ញុំបែកទៅសមរភូមិបានប៉ុន្មាននាក់ហើយ ខ្ញុំឆ្លើយប្រាប់សាមុតវិញថា តាំងពីនោះមកដល់ឥឡូវនេះ បញ្ហាខ្សែរយៈទាក់ទងគឺបានខ្លះដែរមានឈ្មោះ ទឹម អង្គការចាប់អោកជាអនុសង្កាត់ - ស្លឹក -អង្គការចាប់- វែត អង្គការចាប់ - សារិន - ចយ ប៉ុន្តែមកដល់ឥឡូវនេះអង្គការចាប់ខ្លះ នៅខ្លះហើយមិនសូវបានធ្វើសកម្មភាព ឬកសាងកម្លាំងទៀតទេ ដោយភ័យព្រួយបារម្ភខ្លាចអង្គការចាប់ទៀត ។ ពេលខ្ញុំនិយាយចប់ហើយ សាមុតបានបន្តទៀតថា ឥឡូវនេះអង្គការបានចាត់តាំងកងរបស់ខ្ញុំ មកនៅកន្លែងនេះ ពេលនេះយើងត្រូវទាក់ទងគ្នាធ្វើសកម្មភាពទៀត ដើម្បីសំរេចផែនការនៅពេលខាងមុខ ។ រួចពីនិយាយគ្នានេះហើយ សាមុតបានឧទ្ទេសនាម ខ្សែរបស់គាត់តាំងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧នេះ ឲ្យខ្ញុំស្គាល់មានឈ្មោះ :

១ – វែស មុនអង្គការចាប់ខ្លួន ជាអនុប្រធានក្រុមនៅយោធាតំបន់២៥

២ – សារ៉ាន មុនអង្គការចាប់ប្រធានអនុសេនាតូចនៅយោធាតំបន់២៥ ។

៣ – ស៊ាប មុនអង្គការចាប់អនុប្រធានអនុសេនាតូចយោធាតំបន់២៤ ។

៤ – សារឿន ប្រធានអនុសេនាតូច នៅយោធាតំបន់២៤ ។

៥ – ចិន ប្រធានក្រុម នៅយោធាតំបន់ ២៤ ។

៦ – ស៊ុម អនុប្រធានអនុសេនាតូច នៅយោធាតំបន់២៤ ។

បន្ទាប់ពីនុទេសនាមខ្សែរបស់នាត់ឱ្យខ្ញុំទាក់ទងហើយ សាមុតបានណែនាំខ្ញុំថា ខ្សែទាំងអស់នេះបងឯងទាក់ទងចុះ ហើយបងនាំទៅនុទេសនាមឱ្យខ្សែរបស់បងឯងឱ្យគេដឹង ដឹងទាក់ទងគ្នាទៀតមិនអីទេ ខ្ញុំកសាងគេបានយូរហើយ ។ ដល់ឥឡូវនេះគេមកនៅភូមិនេះ ពីព្រោះនៅជិតផ្ទះបងស្រាប់ហើយ បើបងមិនស្គាល់ខ្ញុំទៅប្រាប់ឱ្យដឹងគ្នា ដើម្បីស្រួលដល់ទាក់ទងខ្សែរបស់បងខាងមូលដ្ឋាន និងខ្សែរបស់ខ្ញុំនៅខាងវត ដូចនេះងាយដល់ធ្វើសកម្មភាព និងកសាងកម្លាំងណាស់ ព្រោះអីខ្សែរបស់យើងបានប្រទាក់ខ្សែគ្នា ។ ពីពេលនេះទៅបងឯងខិតខំរកកម្លាំងដែលអាចកសាងបាន ត្រូវខំកសាងឱ្យបានឆាប់ចាប់ពីឥឡូវនេះទៅ ។ ក្រៅពីនេះទៀតលើសីលធម៌នារី បុរស ក៏យើងត្រូវយកចិត្តទុកដាក់ធ្វើដែរ ព្រោះរឿងនេះអូសទាញខាងសតិអារម្មណ៍យ៉ាង យ៉ាងទៀតខាងមនោសញ្ចេតនាបានឆាប់ទៀត ហេតុនេះហើយ - អាចអូសទាញបានឆាប់ ។ មួយទៀតដើម្បីបំផ្លួសង្គម ឱ្យសង្គមនេះទៅជាសង្គមនាយទុនចូលស្រុក ដែលវារកើតរបៀបទបបពុករលួយ ។ ដល់យើងធ្វើអញ្ចឹង ទៅបដិវត្តងាយអីទៅដោះស្រាយទំនាស់បាន ដល់បដិវត្តស្មុគស្មាញទៅ សង្គមថ្មីវា បានមកក្តាប់ម្តង ដែលខុសគ្នាពីសង្គមបដិវត្តបច្ចុប្បន្ន ។ បន្ទាប់ពីនេះខាងផ្នែកប្រជាជនសហករណ៍ ប្រជាជនសហករណ៍បងត្រូវរកវិធីយ៉ាងម៉េចបំផុសទៅមានបញ្ហាប្រចូក-

ប្រចល់ចំនោល បាក់បែកក្នុងផ្ទៃប្រជាជន នេះបានលកម្មប្រយុទ្ធបំពេញភារៈកិច្ច ។ ក្រោយពីនិយាយគ្នាមក សាមុតបាននាំខ្ញុំទៅនុទេលនាមឱ្យខ្មែរគាត់ស្គាល់ នឹងឱ្យខ្ញុំស្គាល់ខ្មែរខាងនឹងនេះ ពេលទៅដល់កន្លែងសាមុត សាមុតបានហៅកម្លាំងរបស់គាត់មកប្រាប់ថា ឥឡូវនេះស.មមិត្តត្រូវទទួលស្គាល់បងវីនេះ គាត់ជាប្រជាជន តែគាត់ជាកម្លាំងរបស់យើង ។ រួចមកសាមុតបានប្រាប់ខ្ញុំថា កម្លាំងនេះហើយបងទាក់ទងចុះគេទទួលស្គាល់បងហើយ រួចហើយក៏បែកគ្នាទៅ ។ បញ្ហាក់តាំងពីយោធាតំបន់២៤មកនៅផ្ទះខ្ញុំមក មិនដែលទៅរួមប្រាស្រ័យក្នុងសហករណ៍ទេ ហើយបង អោកគាត់មិនថាម៉េច គាត់ឱ្យនៅយោធាទាក់ទងកសាងទៀត ។ តាំងពីស្គាល់គ្នាមកកម្លាំងនៅខាងយោធា ខ្ញុំបានប្រមូលខ្មែររបស់សាមុតទៅទាក់ទងខ្មែររបស់ខ្ញុំនឹងបំផុសប្រជាជននៅតាមមូលដ្ឋានផ្សេងៗ អ្នកដែលទៅជាមួយខ្ញុំមាន ទៀន- ចិនសែ ហើយក៏បាននាំគ្នាទៅទាក់ទងបងអោកនៅមន្ទីរសង្កាត់ ពេលខ្ញុំទៅដល់ឃើញគាត់នៅផ្ទះទេ ខ្ញុំបានប្រាប់បងអោកថា នេះកម្លាំងនៅខាងយោធា បងអោកក៏នៅស្ងៀម មួយសន្ទុះក្រោយមកគាត់បានសួរខ្ញុំថា ស.មមិត្តទាំងអស់គ្នាទៅ ខាងណា ខ្ញុំឆ្លើយប្រាប់គាត់វិញថា មកនេះដើម្បីឱ្យបងស្គាល់អ្នកទាំងអស់នេះ ដែល=មកពីខាងយោធា ហើយសុតតែកម្លាំងយើងទាំងអស់នេះ ហើយក្រៅពីនេះទៀតខ្ញុំមិនបាននាំមកទេ នៅអង្គភាពយោធាជិតផ្ទះខ្ញុំមានទៀត ដូច្នេះថាថ្ងៃក្រោយខ្ញុំនាំមកទៀត រួចហើយក៏បែកគ្នាទៅ ។ ហើយបាននាំគ្នាដើរមើលតាមការដ្ឋានដែលប្រជាជនធ្វើ ឆ្លងតាមតាមការដើរមក ខ្ញុំបានទៅដើរមើលសហករណ៍របស់ ខ្ញុំលើកទំនប់ តែរូបភាពខាងក្រៅរបស់បក្សពួកខ្ញុំ ធ្វើជាអ្នកសាមគ្គីជាមួយប្រជាជន

ប៉ុន្តែធាតុពិតរបស់ពួកខ្ញុំបានចូលទៅបំបែកបំបាក់ប្រជាជន អ្នកចូលរួមបំផុសនោះមាន ចិន-សារឿន-សែ ហើយបាននិយាយរឿងនេះ រឿងនោះ ដល់យូរពុទៅខ្ញុំ និងពួកខ្ញុំនិយាយបំបែកបំបាក់ក្នុងផ្ទៃប្រជាជនសមូហភាព មើលថែដែលប្រជាជនមិនចាប់អារម្មណ៍ ខ្ញុំបាននិយាយលើកឡើងពីរឿងបងទឹម ដែលអង្គការចាប់ទៅហើយ ខ្ញុំនិយាយបំភាន់សតិអារម្មណ៍របស់ប្រជាជនថា អង្គការថាធ្វើបដិវត្តន៍ព្រោះមនុស្សឱ្យរស់បែរទៅជាមិនឱ្យរស់ទៅវិញ ចាប់អស់ ដូចបងទឹមគ្មានរឿងអីសោះ គាត់ដឹកគោធ្វើការងារសកម្មណាស់ មិនដែលគាត់ធ្វើអ្វីខុសទេ ស្រាប់តែអង្គការចាប់យកទៅ-បាត់ ដូចនេះបងប្អូនឱ្យតែយើងធ្វើការខុសបន្តិចបន្តួចអង្គការចាប់មិនខានទេ បើសព្វថ្ងៃនេះនៅគ្រប់ភូមិឃុំយើង ឃើញតែអង្គការចាប់គ្មានពេលណាបានសុខទេ ពីពេលនេះទៅបងប្អូនត្រូវប្រុងប្រយ័ត្ន ។ ក្រោយពីចូលបំផុសប្រជាជននេះហើយខ្ញុំ-ចិនសែ-សារឿន បានត្រឡប់មកកន្លែងវិញ ។ ឆ្លងតាមការដើរបំផុសប្រជាជនមក ឃើញថាសភាពប្រជាជនមួយចំនួនមានការព្រួយបារម្ភ តែមួយចំនួនធំមិន មានបញ្ហាអីទេ មួយចំនួនតូចដែលមិនពេញចិត្តជាមួយបដិវត្តមានរកម្មរកូលនៅក្នុងសហករណ៍ទៀត ។

ដល់ខែ១៥ ឆ្នាំ ១៩៧៧ ឆ្លងតាមការដើរបំផុស និងធ្វើសកម្មភាពនៅតាម មូលដ្ឋានមកខ្ញុំកសាងបានម្នាក់ឈ្មោះ លន់ ជាប្រជាជននៅសហករណ៍ភូមិរាក់ជែ ឃុំរាក់ជែ ស្រុកបាភ្នំ-តំបន់២៤ ។ ហើយខ្ញុំបានទៅរាយការណ៍ឱ្យសាមុត-បងអោកជាគណៈសង្កាត់ ។ មតិរបស់សាមុតប្រាប់ខ្ញុំ និងបងអោកថា ឥឡូវនេះអង្គការជិតផ្លាស់កន្លែងខ្ញុំហើយ ប៉ុន្តែទោះជាអង្គការដកខ្ញុំពីកន្លែងនេះយ៉ាងណាក៏ដោយបងទាំង

អស់នៅខាងក្រោយ ត្រូវបន្តសកម្មភាពទៀត នឹងទាក់ទងគ្នាឱ្យបានច្រើន ។ មុននឹងបែកគ្នាសាមុតបានឱ្យកាំភ្លើងអាកា១ដើម មកខ្ញុំជាមួយបងអោក សំរាប់ដើរដំរាមកំហែងប្រជាជន ហើយសាមុតបានប្រាប់ថា ឥឡូវនេះបងយកប្រើប្រាស់សិនទៅ ចាំថ្ងៃក្រោយយើងនឹងបានកាន់គ្រប់ដៃហើយ ដើម្បីដើរបាញ់បំភ័យប្រជាជននៅក្នុងសហករណ៍ ។ តាំងពីសាមុតឱ្យកាំភ្លើងមក ខ្ញុំបានទៅនាំកម្លាំងរបស់ខ្ញុំដើរធ្វើសកម្មភាពមានឈ្មោះ ចយ - សារិន - ន្ទាំង - ឯកម្លាំងខាងយោធាមានឈ្មោះ វឿនចិន វែស - ស៊ុម - បានទៅលួចបាញ់បំភ័យប្រជាជននៅសហករណ៍ភូមិរាក់ដៃ ធ្វើឱ្យសភាពច្របូកច្របល់ក្នុងប្រជាជន ។ ក្រោយពីនេះមកទៀតបានលួចកាប់ភ្លឺស្រែ បំផ្លាញស្រូវអស់ ២ហិកតាទៀត ។ ក្រោយពីនេះមកទៀត សាមុតបានស្នើបង អោកស៊ុំគោក្របីជប់លៀង ដើម្បីឱ្យបងអោកជួយផ្ដល់គោក្របីជូនមាន់ទាមកជប់លៀងពេលបែកគ្នាទៅព្រំដែនវិញ ។ មួយទៀតសាមុតស្នើផងរ បញ្ហានារីកងចលតមកលេងសិល្បៈនៅកន្លែងជប់លៀងលាទៅព្រំដែន ។ រួចហើយបងអោកបាន រកគោក្របីបានខ្លះ ហើយនាំយកមកឱ្យសាមុតនៅចុងភូមិជិតផ្ទះខ្ញុំនោះ ។ ខ្ញុំសូមប្រាប់ពីប្រជាជនកាលដែលបងអោកឱ្យគោក្របីមកយោធាជប់លៀងគាត់និយាយថាកងពលអីពុករលួយម៉្យាងនឹង ដើរដែតចាប់កូនចៅគេគ្មានដឹងក្បួន - គ្មានដឹងចាស់អីទេឱ្យតែឃើញចាប់ៗ រួចហើយគាត់បានប្រាប់បងអោកព្រមគ្នាថា មិនឱ្យធ្វើតែរបៀ ប នេះ ដើរទៅរកភូមិឯណាផ្សេងទៀតទៅ បើរកភូមិនេះមិនឱ្យគោក្របីស៊ី ទេ នាំតែខាតរបស់សហករណ៍ ។ រួចហើយបងអោកមិនហ៊ានយក ក៏ទៅប្រាប់សាមុតថា បញ្ហារកគោក្របីប្រជាជនតាមសហករណ៍មិនសំរេចឱ្យយើងទេ គាត់ថាកងពលយើង

ពុករលួយណាស់ ដូច្នេះគាត់មិនឱ្យគោក្របីមកយើងទេ ហើយខ្ញុំមិនហ៊ានឱ្យគោក្របីទេ ខ្លាចប្រជាជនគេបះបោរ ។ រួចហើយសាមុតថា បើមិនឱ្យគោក្របីស៊ីទេ ចាំមើលយួនវៃចូល ទុកឱ្យយួនចូលចាប់អស់ម្ដង គ្រាន់តែកងទ័ពគ្នាចាប់កូនបណ្ដើង មិនឱ្យគោក្របីស៊ីដែរ ចាំមើលបើកទ្វារឱ្យយួនចូលម្ដងទៀតទៅណា ។ សាមុតបន្តថា ចាំទៅស៊ីអី ឱ្យកងទ័ពដើរទៅបាញ់យកមកស៊ីបានហើយ គ្មានអ្នកណាហ៊ានធ្វើអីអញ ។ សាមុតបានចាត់តាំងអ្នកដើរបាញ់គោក្របីនោះមានឈ្មោះ សារឿន - ចិន - ស៊ុម ហើយបងអោកក៏យល់ស្របតាមសាមុតលើកឡើង ក៏បែកគ្នាទៅ ។ ក្រោយពីដាក់ផែនការនេះមក កងទ័ពសាមុតបានទៅលួចបាញ់គោប្រជាជនបានពីរក្បាលសុទ្ធតែគោឈ្មោល ដែលប្រជាជនទើបដាក់ពីភ្ជួររាស់ ដែលឱ្យស៊ីតាមទីព្រៃ ។ ហើយសាមុតបានយកមកកន្លែង សាមុតបានអញ្ជើញកម្លាំងខ្ញុំមកទាំងអស់មានឈ្មោះបងអោក សារិន - ភ្នាំង - ចយ -មកចូលរួមក្នុងការជប់លៀងនេះ ពេលជប់លៀងនេះគ្មានទ័ពមកពីណាច្រើនទេ សុទ្ធតែកងទ័ពរបស់សាមុត ពេលជប់លៀងសាមុតបានស្រូកកងទ័ព ពីភូមិឆ្ងាយទៅជិតកងចល័ត ហើយសាមុតបានឱ្យបងអោកទៅអញ្ជើញកងចល័តមក ជប់លៀងដែរ សាមុតមិនឱ្យអញ្ជើញច្រើនពេកទេនាំតែបែកការសម្ងាត់នេះ ។ ការជប់លៀងនេះអស់រយៈមួយយប់ សាមុតមិនឱ្យកងទ័ពគាត់នេះមកលេងទាំងអស់គ្នាទេ យាមខ្លះ លេងខ្លះ ដើម្បីកុំឱ្យបែកការណ៍ ទៅដល់ប្រជាជន ឬអ្នកបដិវត្ត-មកចូលកន្លែង ។ សភាពការណ៍យប់នោះឃើញថា យុវជនកងទ័ពរបស់សាមុត និងយុវនារីកងចល័ត ប្រឡូកប្រឡល់មិនដឹងអីពុះទេ ពេលយប់នឹង ពិសេសរឿងសីលធម៌គ្នាមានសភាពមិនបដិវត្តច្រើន ។ ដល់ព្រឹកឡើងទើបសាមុតឱ្យនារីកងចល័តនេះនាំ

គ្នាទៅអង្គភាពគេវិញ ។

ដល់សភាពការណ៍វ៉ៃយួនទៅនៅក្នុងឆ្នាំ ១៩៧៩ ក្នុងចុងឆ្នាំ សាមុតបានចេញមកសមរភូមិ ហើយកងទ័ពរបស់សាមុតចេញទៅអស់ដែរ មុនពេលចេញទៅខ្ញុំបានទាក់ទងជាមួយសាមុតសុំចូលយោធា ព្រោះខ្ញុំនៅភូមិនេះមិនដឹងទាក់ទងណាទៀត ទេ ព្រោះអង្គការត្រូវការកម្លាំងទៅសមរភូមិអស់ខ្លួនហើយ ពេលនោះបងអាក មិនឱ្យខ្ញុំចូលទេ ។ ហើយខ្ញុំបានសុំសាមុតរត់ចូលទ័ព សាមុតបានប្រាប់ខ្ញុំថា បងឯងកុំអាលទៅអី ចាំដល់ខ្ញុំវ៉ៃយួនឈ្នះ ឬក៏យួនវ៉ៃឈ្នះ ចាំខ្ញុំមកយកបងទៅដែរ ពេលនេះដែលបងនៅខាងក្រោយធ្វើម៉េចលក្ខការ ហើយទាក់ទងជាមួយកម្លាំងរបស់បងធ្វើសកម្មភាពទៀតទៅ ។ ខ្ញុំក៏បានត្រឡប់មកផ្ទះវិញ សាមុតបានទៅសមរភូមិ ។ ពេលនៅផ្ទះបានប៉ុន្មានថ្ងៃទើបឃើញពុកខ្ញុំ មកពីរួចឃុំឃាំងរបស់បក្សដែរ ពុកខ្ញុំមកដល់ឃើញគាត់ចាស់ហើយ ឈឺទៀត ពេលមកដល់មិនបានធ្វើការអីទេ នៅតែផ្ទះ ព្រោះគាត់ឈឺ ដោយគ្រាំគ្រានឹងដំបង ។ ដល់មានថ្ងៃមួយក្រោយពីដែលខ្ញុំមកលេងជាមួយគាត់ ឃើញប្អូនរបស់ខ្ញុំមកហៅខ្ញុំ ឱ្យមកផ្ទះរបស់គាត់ ពេលមកដល់ ខ្ញុំឃើញគាត់អង្គុយលើផ្ទះ ។ ហើយគាត់បានហៅខ្ញុំទៅជិត គាត់បានសួរខ្ញុំថា ម៉េចទៅអា កាលអញគេចាប់យកទៅដាក់គុកនោះ តើអាឯងដាច់ខ្សែជាមួយ អ្នកណាទៀតឬមួយអត់ ខ្ញុំឆ្លើយប្រាប់វិញថា កាលពីពុកឯងអង្គការចាប់នោះខ្ញុំមិនមានបញ្ហាអីដាច់ខ្សែទាក់ទងរបស់ខ្ញុំទេ អស់ខ្សែមួយខ្ញុំទាក់ទងបានខ្សែមួយទៀតបើដាច់ដាច់កាលអង្គការចាប់ពុកឯងស្លាម ព្រោះខ្ញុំពេលនោះភ័យព្រួយខ្លាចអង្គការដឹងខ្លួនខ្ញុំបំរើផែនការនេះ ។ ហើយខែក្រោយនេះត្រូវអង្គការចាប់ខ្លះ ខ្លះបែក-

គ្នា ឯបងទាំងបីនាក់នោះបែកគ្នាអស់ហើយ ដោយគាត់មានគ្រួសារទៅនៅភូមិ ផ្សេង ហើយកម្លាំងសព្វថ្ងៃនេះមានឈ្មោះ បងអោក គាត់ជាគណៈសង្កាត់-សាវិន ចយ-ឆ្នាំង ដូច្នេះអាចមានលទ្ធភាពបន្តទៀតបាន ។

ក្រោយដែលខ្ញុំនិយាយហើយ ពុកខ្ញុំបាននិយាយពាក្យដែលនាំថា កូនឯងនៅក្មេង ណា ឪពុកចាស់ហើយ ពីពេលនេះទៅ កូនត្រូវគោរព ហើយអនុវត្តជូនពុកផង ។ ព្រោះឪពុកគេចាប់យកទៅដាក់គុកវាយដំប្រចាំថាក់ច្រើន ហើយសាប់យ៉ាមឪពុកក៏ អស់ដែរ ដូចនេះកូនត្រូវចាំពាក្យនេះ ហើយបក្ខសកម្មភាព និងខ្សែទាក់ទងរបស់កូនទៀត ដើម្បីសំរេចគោលបំណង សេចក្តីសប្បាយរបស់កូនទៅថ្ងៃអនាគតរបស់ រូបកូន និងប្អូនកូនក្រោយពុទៀត នៅក្នុងរបបនេះមិនភ្លឺស្វាងទេ ទាល់តែ កូន នាំគ្នាប្រឆាំងរបបនេះ ហើយកសាងរបបមួយទៀត ទើបបានសេចក្តីសុខសប្បាយ ។ ហើយក៏បានបែកពីឪពុកខ្ញុំទៅផ្ទះវិញ ។ នៅក្នុងចុងឆ្នាំ ១៩៧៧នេះ ខ្ញុំមិនបានធ្វើ សកម្មភាពអីទេ ព្រោះបក្សពួកខ្ញុំត្រូវអង្គការដកយកទៅបំរើសមរភូមិខ្លះ ខ្លះមិន បានជួបគ្នា ហើយនៅក្នុងចុងឆ្នាំនេះអង្គការតាំងតែចាប់បន្តបន្ទាប់ ។

ដល់ឆ្នាំ ១៩៧៨ ក្រោយពីបរាជ័យរបស់យួននៅថ្ងៃទី ៦.មករា- សាមុត បាន មកយកខ្ញុំទៅនៅកងទ័ពតំបន់ទៀត ហើយខ្ញុំបានទៅសុំបងអោកចូលធ្វើយោធានឹងគេ ហើយ គាត់បាននិយាយប្រាប់ខ្ញុំថា ឥឡូវនេះអង្គការថា អ្នកមានគ្រួសារអង្គការ ឱយផ្អាកសិន គឺអង្គការរើសយកតែអ្នកនៅលីវទេ ដើម្បីកុំឱយគេអ្នកមានគ្រួសារថា មានលតិអារម្មណ៍ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំទៅឥឡូវនេះហើយ ។ ខ្ញុំបានគិតក្នុងចិត្ត ថា បើនៅមិនដឹងទៅទីពឹងអ្នកណាទេ ខ្សែទាក់ទងក៏មានតិច ពឹងទៅឪពុក ខ្ញុំ

ឪពុកចាស់ បើម្ដាយចាស់ធ្វើការមិនកើតផង ពឹងទៅបងអង្គការដកចេញមិនឱ្យខ្ញុំនៅជិតគ្នាទៀត ដូច្នេះខ្ញុំមានតែផ្លូវមួយទេ គឺរូបខ្ញុំមានតែរត់ចូលទៅធ្វើកងទ័ពទេ ទើបមានខ្សែច្រើន ព្រោះអីខ្សែរបស់ខ្ញុំនៅអង្គភាពយោធាច្រើនដែរ ។ ដល់សុំមិនបានអញ្ចឹងមក ខ្ញុំក៏ត្រឡប់មកផ្ទះវិញ ។

ក្រោយមកទៀត ទើបឃើញសាមុតមកលេងផ្ទះខ្ញុំ ពេលនោះខ្ញុំបានសួរសាមុតថាកងទ័ពឥឡូវនេះនោះនៅឯណា រួចហើយសាមុតបានប្រាប់ខ្ញុំថា កងទ័ពបច្ចុប្បន្ននេះនោះនៅប្រចាំសមរភូមិត្រពាំងត្រាម ។ បន្ទាប់ពីខ្ញុំសួរមកហើយ ខ្ញុំបានសុំសាមុតទៀត ដើម្បីចូលធ្វើយោធា ព្រោះខ្ញុំនៅភូមិប្រជាជនគេកាន់តែឯកា ខ្ញុំទ្រឹងពុជារីរៀងរាល់ថ្ងៃ ដោយប្រជាជនសហករណ៍ខ្ញុំ គេពិនិត្យឃើញខ្ញុំកន្លងមកធ្វើសកម្មភាពប្រឆាំងបក្ស និងបង្កិចបំផ្លាញទ្រព្យសម្បត្តិរបស់សហករណ៍ ។ ហើយសាមុតថា មិនអីទេ ចាំមើលបន្តិចទៅ កងទ័ពគេមកសំរាកខាងក្រោយចាំបងទៅនៅក្នុងអង្គភាពរបស់ខ្ញុំតែម្ដង ដូច្នេះចាក់ចងគ្នាធ្វើអីបានតាមចិត្ត ។ រួចហើយសាមុតបានលាខ្ញុំត្រឡប់ទៅអង្គភាពវិញ ខ្ញុំក៏ត្រឡប់មកផ្ទះវិញដែរ ។

ដល់ខែ ២ ឆ្នាំ ១៩៧៨ ខ្ញុំត្រូវចេញពីភូមិទៅនៅយោធា ពេលទៅនេះខ្ញុំមិនបានប្រាប់អ្នកណាទេ ដល់ពីរបីថ្ងៃទើបខ្ញុំសរសេរសំបុត្រមកប្រាប់អ្នកទទួលខុសត្រូវនឹងគ្រួសាររបស់ខ្ញុំ ។ ការទៅនេះខ្ញុំសំដៅកន្លែងដែលសាមុតបានប្រាប់ខ្ញុំថាកន្លែង ង ត្រពាំងត្រាម ដូច្នេះខ្ញុំបានទៅនៅចំអង្គភាពរបស់សាមុតមែន ទៅដល់សាមុតបានចាត់តាំងឱ្យខ្ញុំនៅអនុសេនាតូចលេខ ៥ អនុសេនាធំលេខ ០.២០ វរៈសេនាតូច-លេខ ៧០៣ វរៈសេនាធំ ២៧០ យោធារបស់តំបន់ ២៥ ប្រចាំនៅក្នុងសមរភូមិត្រ

តាំងព្រាម ៗ

សាមុតបានហៅកម្លាំងរបស់គាត់ និងរូបខ្ញុំឱ្យចូលក្នុងការអប់រំនេះដែរ កម្លាំង
ខាងសាមុតមានឈ្មោះ យន - មឿន - ហើយនឹងកម្លាំងចាស់ទៀតមានៈសារឿន
ចិន - ស៊ុម នៅក្នុងទីនោះ សាមុតបានលើកឡើងថា ឥឡូវនេះយើងកាន់តែបាន
កម្លាំងច្រើនឡើង សកម្មភាពយើងធ្វើក្នុងនេះក៏កាន់តែប្រឡូកប្រឡល់ដែរ ឯបង រី
ដែលទើបមកពីភូមិថ្មីអញ្ចឹងមិនទាន់ដឹងទេ ៗ សភាពការណ៍បដិវត្តន៍វិញ ដូចស.ម -
ឃើញស្រាប់ហើយ សន្ទុះនៃការបោសសំអាតខ្មែររបស់យើងនៅភូមិភាគនេះកាន់តែ
ខ្លាំងជាងមុនទាំងអស់ ហេតុដូច្នេះទាល់តែយើងឃើញចំណុចខ្សោយ ខ្លាំងរបស់យើង
ក្នុងការធ្វើទើបដណ្តើមបានជ័យជំនះ បើមិនអញ្ចឹងទេពិតជាបរាជ័យទៀតដូចយួន ទីវ៉
នៅចុងឆ្នាំ ១៩៧៧នេះអញ្ចឹង មកពីអីគឺមកពីកម្លាំងរបស់យើងខាងក្នុងមិនទាន់ មាន
ខ្សែសង្វាក់ ហើយត្រូវកងទ័ពអង្គការវ៉ៃកំចាត់ទៀត ៗ ហើយបងរី ចាប់តាំង
ពីពេលនេះ បងត្រូវទាក់ទងកម្លាំងនៅក្នុងអង្គប្រជុំនេះធ្វើសកម្មភាពសិនចុះ កម្លាំង
យើងនៅមានច្រើនទៀត ខ្ញុំមិនទាន់ប្រាប់បងទេ ព្រោះអីបងទើបតែមកដល់ ថ្មី
ហើយត្រូវទាក់ទងគ្នា ៥នាក់នេះធ្វើសកម្មភាពទៅ ៗ សាមុតបន្តទៀតលើក ពីស
ភាពការណ៍នៅក្នុងតំបន់ ២៤នេះ ក្រោយពីមានសភាពការណ៍វៃយួនមក អង្គការ
បានបោសសំអាតខ្មែរនៅតំបន់ ក៏ដូចនៅភូមិភាគយើងដែរគគ្រឹកគគ្រេងជាទៀង
រាល់ថ្ងៃ ប៉ុន្តែនៅតំបន់យើងនេះ អង្គការមិនទាន់ឃើញល្វចាប់ទេ ព្រោះ -
យើងមានបក្ខពួករឹងមាំណាស់ តាំងពីអ្នកទទួលខុសត្រូវតំបន់ក៏អត់ឃើញអង្គការចាប់ដែរ
ក្នុងកងទ័ពក៏ដូចនៅតាមមូលដ្ឋានដែរ ៗ ហើយមានតែដកកម្មាភិបាលពីតំបន់២៤យើង

ទៅក្តាប់តំបន់ផ្សេងៗទៀត ទាំងកម្មាភិបាលកងទ័ព នាំងកម្មាភិបាលតំបន់ និងស្រុក ទៀត ។ បន្ទាប់ពីលើកសភាពការណ៍រួចហើយ សាមុតបានលើកផែនការឱ្យអនុវត្ត សាមុតបាននិយាយថា ឥឡូវនេះយើងត្រូវធ្វើយ៉ាងណា កសាងកម្លាំងនៅក្នុង អង្គភាពយើងនេះក្នុងមួយខែធ្វើម៉េចឱ្យបានពីរនាក់ទៅបីនាក់ទៀត ។ ក្រៅពីនេះ ទៀត យើងត្រូវយកចិត្តទុកដាក់ធ្វើសកម្មភាពបង្កបំផ្លាញរបស់របរនៅក្នុងអង្គ ភាពយោធាយើងនេះ ដូចជាគ្រាប់- កាំភ្លើង- ពិសេសជាងនេះទៅទៀតបំផ្លាញ កម្លាំងបដិវត្តពេលចូលសមរភូមិឬនៅតាមភូមិឃុំ យើងត្រូវលួចបាញ់ម្តងមួយ ម្តងពីរ ដែលអីទៅអនាគតកម្លាំងនេះត្រូវខ្ទេចខ្ទីអស់ ។ សាមុតបន្តពោលទៀតថា ពេលចូល សមរភូមិស.មមិត្តទាំងអស់ត្រូវយកចិត្តទុកដាក់បំផុសយុទ្ធជនដែលទើបអង្គការជ្រើសរើសថ្មី ឱ្យរត់ចោលសមរភូមិ ដើម្បីបើកដៃឱ្យយួនចូលទៀត ។ ហើយក៏បែកគ្នាទៅៗ ក្រោយពីបែកគ្នា ទៅសាមុតបានចាត់តាំងខ្ញុំជាអ្នកដើរស្រួតពិនិត្យកន្លែងនិមួយៗ មាន សកម្មភាពយ៉ាងម៉េច ប៉ុន្តែនាទីខ្ញុំនៅតែយុទ្ធជនដដែលទេ ។ ដូច្នេះការងារអី ខ្ញុំបានទាក់ទងនឹងទាំងអស់នៅតាមកងអនុសេនាធំរបស់វរៈសេនាតូចខ្ញុំ ។

ក្រោយពីបានទទួលផែនការនេះហើយ ប្រហែលជាចុងខែ ៣ ឆ្នាំ ១៩៧៨ ពេលនេះអង្គការកំណត់ឱ្យវៃយួនដែលនៅតាមព្រំដែនមុខសញ្ញាត្រពាំងព្រាមឱ្យវា ឥតឱ្យអស់នៅខែ ៤ នេះ ដើម្បីយកកងទ័ពមកលេងបុណ្យ និងទទួលអំណរបុណ្យចូល ឆ្នាំផង ពេលនេះសាមុតបានហៅខ្ញុំ- សារឿន- ឈន- មកអប់រំថា ឥឡូវនេះត្រូវ អង្គការឱ្យយើងវៃយួនឱ្យចេញពីព្រំដែនឆ្ងាយ ដើម្បីធ្វើបុណ្យទទួលអំខួបនៅថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៨នេះ តែទិសដៅរបស់យើងគឺវៃឱ្យដាច់អី នាំតែគេឃ្លាតមក

ឆ្ងាយពីយើងទាក់ទងទេ ដូច្នេះដើម្បីកុំឱ្យសំរេចផែនការនេះបានស.មមិត្តទាំងអស់ ត្រូវយកចិត្តទុកដាក់ត្រៀមខ្លួន ធ្វើសកម្មភាពបំផ្លិចបំផ្លាញកម្លាំងបដិវត្ត និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់បក្សថែមទៀត ។ ឯមិត្តក្រៅពីនេះដូចជាចិន- ស៊ុម មឿន ជាអ្នកទាក់ទងយួនជាមួយខ្ញុំ ដើម្បីធ្វើឱ្យយួនដឹងខ្លួនមុន កុំឱ្យកម្លាំងគេខូចខាតអី ។ រួចហើយក៏បែកគ្នាទៅ ។ ក្រោយមកបានប្រហែលជាពីរបីថ្ងៃត្រូវចូលសមរភូមិមែន ហើយខ្ញុំបានអនុវត្តធ្វើសកម្មភាពតាមការណែនាំរបស់សាមុតជាមួយឈន សារឿន ការចូលវាយទៅសមរភូមិត្រពាំងព្រាមនេះ មិនបានចូលទៅដល់ផងត្រូវកងទ័ពយួនដឹងមុន ហើយបាញ់មកលើកងទ័ពតំបន់២៥ ដោយសាមុតបានទៅទាក់ទងយួនមុន សមរភូមិមិនបានសំរេច ។ ខ្ញុំបានធ្វើសកម្មភាពនៅក្នុងសមរភូមិជាមួយ ឈន សារឿន ពេលចូលខ្ញុំបំផុសឱ្យយុទ្ធជនដែលទើបមកថ្មីរត់អស់ច្រើន ក្រៅពីនេះខ្ញុំបានបំផ្លាញគ្រាប់រំសេវដែលយុទ្ធជនខ្លាចសមរភូមិរត់ចោល ខ្ញុំមិនយកទៅទុកដាក់ទេបានយកទៅបោះចោល ។

ដល់ចុងខែ ៤ និងដើមខែ ៥ ឆ្នាំ ១៩៧៨នេះ ឃើញសាមុតបានហៅខ្ញុំ ទៅប្រជុំនៅកន្លែងអនុសេនាធំ ពេលខ្ញុំទៅដល់ឃើញមនុស្សច្រើនប្រហែលជាមួយកងអនុសេនាធំ ប៉ុន្តែខ្ញុំស្គាល់មានឈ្មោះ សាវ៉ែម ប្រធានអនុសេនាធំ - សារ៉ាន់ ប្រធានអនុសេនាតូច - សារឹមអនុលេខាវរៈសេនាធំ - អ៊ឹបអនុលេខាវរៈសេនាតូច - សារ៉ុន ប្រធានអនុសេនាធំ - មឿន - យុទ្ធជន - ឈនមេពួកខ្ញុំ - នីជាយុទ្ធជន - ចិនប្រធានក្រុម - សារឿន ប្រធានអនុសេនាតូច - ស៊ុម អនុប្រធានអនុសេនាតូច ។ ថនប្រធានក្រុម - ផាន មេពួក - គៀនជាយុទ្ធជន - ក្រៅពីខ្ញុំស្គាល់នេះ មាន -

ច្រើនទៀតមកពីគ្រប់អនុសេនាធំ តែខ្ញុំមិនស្គាល់អស់ ។ កម្លាំងនេះប្រជុំនៅជិតមន្ទីររបស់វរៈសេនាតូច នៅលើមរភូមិត្រពាំងព្រាម ។ ពេលនោះខ្ញុំឃើញ បងហួយជាលេខាវរៈសេនាធំ ដោយសា បងសាមុតប្រាប់ ។ ប្រជុំនេះអស់រយៈមួយថ្ងៃទំរាំសំរេច ហើយក្រៅពីកន្លែងប្រជុំមានអ្នកយាមទៀត មិនឱ្យអ្នកចូលទេ ខ្លាចបែកការណ៍ ប្រជុំនេះចំរុះគ្នា ទាំងយុទ្ធជន-កម្មាភិបាល ប៉ុន្តែយុទ្ធជនច្រើនជាងកម្មាភិបាល ។ ដែលមានបងហួយ ជាប្រធានអង្គប្រជុំ គាត់លើកឡើងក្នុងអង្គប្រជុំមាន៣បញ្ហា គឺ ៖

១– បញ្ហាធ្វើសង្គ្រាមឈ្លប ដើម្បីទីរំកងទ័ពរបស់អង្គការដែលប្រចាំនៅភូមិភាគបូព៌ា ។

២– គាត់លើកឡើងអំពីផែនការបរាជ័យនៅពេលថ្មីៗនេះ និងត្រៀមមនុស្សធ្វើសង្គ្រាម និងទប់ទល់ផែនការរបស់អង្គការបច្ចុប្បន្ន ។

៣– ត្រូវរៀបចំកម្លាំងតទៅទៀតឱ្យបានច្រើន ហើយឱ្យកងទ័ពដែលអប់រំបាននេះត្រៀមខ្លួន ។ ក្រៅពីនេះទៀតធ្វើសកម្មភាពបផ្លិចបំផ្លាញ

នេះវិរៈអង្គប្រជុំរបស់បងហួយ ដែលគាត់ឯកភាពលើកជាមួយបង សារឹម ជាអនុលេខាវរៈសេនាធំ ។ បងហួយ លើកឡើងបញ្ហាទីមួយថា បញ្ហាធ្វើសង្គ្រាមឈ្លប គឺត្រូវរៀបចំកម្លាំងនៅគ្រប់កន្លែងឱ្យបានច្រើន បើអង្គការមានផែនការវ៉ៃយួនកន្លែងណា ដូច្នេះកម្លាំងកសាងបាននេះត្រូវតែបផ្លិចបំផ្លាញកម្លាំងបដិវត្ត និងឈ្លបបាញ់កងទ័ពអង្គការទៀត ពេលដែលចូលមកក្នុងតំបន់យើង ឬក្រៅតំបន់ ហេតុនេះកម្លាំងនឹងត្រូវអនុវត្តឈ្លបបផ្លិចបំផ្លាញ ។ បញ្ហាផែនការបរាជ័យនៅក្នុងឆ្នាំ ៧៨

នេះគឺ កម្លាំងនៅភូមិភាគបូព៌ាទាំងមូលត្រូវអង្គការប្រមូលចាប់ដាបន្តបន្ទាប់ ហើយឯផែនការថាធ្វើរដ្ឋប្រហារវាយរំលំបក្សកុម្មុយនីស្តកម្ពុជានោះ ក៏មិនបានសំរេចផែន- មកពីកម្លាំងយើងត្រូវអង្គការផ្លាស់ការបោសសំអាតជាទូទៅក្នុងភូមិភាគយើងនេះ ។ ប៉ុន្តែសង្គ្រាមរបស់យើងទប់ទល់ផែនការត្រូវអនុវត្តឱ្យបានជាប់នៅគ្រប់អនុសេនាធំវរសេនាតូចទាំងអស់ ដើម្បីស្លាការបរាជ័យរបស់យើងថ្មីៗនេះ ។ បញ្ហារៀប ចំកម្លាំងបច្ចុប្បន្ន បច្ចុប្បន្ននៅគ្រប់កងអនុសេនាធំកម្លាំងមានទាំងប៉ុន្មានត្រូវរៀបចំឱ្យមានការប្រុងប្រៀប ក្រែងមានផែនការអីទៀតនៅក្នុងឆ្នាំ ១៩៧៨នេះមកដល់យើងរាល់គ្នាអនុវត្ត ។ ក្រៅពីនេះទៀតត្រូវធ្វើសកម្មភាពបង្អិចបំផ្លាញរបស់របបបដិវត្តទៀត ធ្វើម៉េចឱ្យតែបដិវត្តងាកទៅណេះល្អូគល្អាញ ងាកទៅណោះល្អូគល្អាញ ។

រួចហើយបងប្អូន បាននិយាយបន្តបញ្ជាក់អំពីផែនការ និងសកម្មភាពដែលត្រូវ ធ្វើនៅបច្ចុប្បន្ននេះគឺ បញ្ហាកសាងមនុស្សថ្មី ស.មមិត្តគ្រប់កងអនុសេនាធំត្រូវអនុវត្តកសាងកម្លាំងឱ្យបានច្រើន ប៉ុន្តែមិនចាប់ត្រឹមកងអនុសេនាធំ- អនុសេនាតូច -ប្រធានក្រុម យុទ្ធជនក៏ត្រូវយកចិត្តទុកដាក់ក្តាប់បញ្ហាកសាងមនុស្សថ្មីនេះដែរ ជាផែនការកំណត់កសាងក្នុងមួយខែមួយអនុសេនាធំត្រូវឱ្យបានពីរទៅប្រាំនាក់ ព្រោះអីកម្លាំងនៅតាមកន្លែងរបស់យើងអាចកសាងបានហើយ ព្រោះភាគច្រើនអាចបំផុសទៅបាន ។ បញ្ហាធ្វើសកម្មភាពបង្អិចបំផ្លាញបដិវត្ត នៅគ្រប់អង្គភាពទាំងអស់ត្រូវយកចិត្តទុកដាក់ធ្វើសកម្មភាពនេះថែមទៀត ធ្វើម៉េចផ្ទុកលតិអារម្មណ៍របស់មហាជន ឱ្យគេ ល្អូគល្អាញនឹងភារៈកិច្ចរបស់បដិវត្ត ។ ម្យ៉ាងទៀតពេលចូលសមរភូមិត្រូវបំផុសឱ្យយុទ្ធ

ផលទត់ ឬបញ្ចាំបំផ្លាញ ។ ដោយខ្ញែកមកទៀតគឺស.មមិត្តទាំងអស់ត្រូវគិត គូរផែនលើបញ្ហាទាក់ទងជាមួយប្អូន តទៅនេះខ្ញុំសូមចាត់តាំងអ្នកដែលត្រូវទាក់ទងប្អូនមានដូចតទៅ : ស.មមិត្តសាមុត- ស.មមិត្តអ៊ីប- សារីម៉ ប្រធានអនុសេនាធំ ។ ទាំងបីនាក់នេះត្រូវសហការគ្នាទាក់ទងប្អូនឱ្យបាន ហើយផែនការអ៊ីយ៉ាងម៉េចត្រូវពិនិត្យហើយពិភាក្សាជាមួយគេ ។ ប៉ុន្តែស.មមិត្តត្រូវរាយការណ៍ឱ្យខ្ញុំដឹងផង ផែនការអ៊ីយ៉ាងម៉េចឱ្យដឹង ដើម្បីងាយស្រួលដល់យើងធ្វើរដ្ឋប្រហារទៀត ។ ក្រោយពីប្រជុំលើកផែនការហើយ បងហួយ បានប្រកាសប្រាប់អ្នកចូលរួមក្នុងអង្គប្រជុំថា ចាប់ពីក្រោយប្រជុំនេះទៅ ស.មមិត្តដែលបានមកចូលរួមប្រជុំនេះត្រូវរៀបចំខ្លួនឱ្យហើយ ព្រោះផែនការពេលបច្ចុប្បន្ននេះកាន់តែប្រប្រួលហើយ ដូចនេះត្រូវរៀបចំឱ្យបានគ្រប់គ្នា ចាំមានផែនការអ៊ី ខ្ញុំមកប្រាប់បានភ្លាម អញ្ជឹងបានផែនការឆាប់ បំរើបានទាន់ពេលវេលា ។ រួចហើយរៀបចំបិទអង្គប្រជុំ បងហួយបានសួរមតិអង្គប្រជុំថា ផែនការដែលខ្ញុំលើកទាំងប៉ុន្មាននេះ មានស.មមិត្តណាចង់បន្ថែមទេ ពេលនោះអង្គប្រជុំយល់ស្របតាមបងហួយលើកឡើង ហើយក៏បានរំសាយទៅ ពេលល្ងាចបន្តិចៗ ហើយកម្លាំងដែលចូលរួមប្រជុំ ក៏បានបែកទៅតាមអង្គភាពរបស់ខ្លួនវិញ ។ ខ្ញុំ និងបងសាមុតបានមកកន្លែងវិញដែរ ។

តាំងពីក្រោយប្រជុំនេះមក កម្លាំងដែលបានចូលរួមទាំងប៉ុន្មាននោះ មិនធ្វើការងារទេ មួយថ្ងៃមួយថ្ងៃគិតតែដេក ចាំមើលផែនការពីបងហួយដាក់ឱ្យអនុវត្ត-ពេលនេះធ្វើឱ្យយុទ្ធជនខ្លះមានសតិអារម្មណ៍ ហើយរាយការណ៍ទៅឱ្យអ៊ីប ជាអនុ សេនាវរៈសេនាតូច ដើម្បីឱ្យបងអ៊ីបស្តីឱ្យអ្នកដេកនោះ ប៉ុន្តែបងអ៊ីបមិនស្តីឱ្យអ្នក សំ

រាកនោះទេ  គឺគាត់ស្ដីឱ្យអ្នកដែលទៅរាយការណ៍វិញ  ដូច្នេះធ្វើឱ្យសតិអារម្មណ៍យុទ្ធជនស្មុគស្មាញ ។

ដល់សភាពការណ៍អាភីម  ខ្ញុំត្រូវអង្គការដកមួយអនុសេនាធំរបស់ខ្ញុំទៅនៅការពារក្រុំផែន  ពេលមានសភាពដំបូងខ្ញុំមិនបាននៅទេ  បានប្រហែលជាពីរបីថ្ងៃបងសាមុតបានហៅកម្លាំងរបស់ខ្ញុំទាំងនៅក្នុងអនុសេនាធំមកប្រាប់ថា  ឥឡូវនេះយើង ត្រូវរៀបចំខ្លួនទៅទីវ័យួននៅក្រុងទីព្រវែង  ព្រោះអីយួនចូលនៅទីនោះច្រើនដែរ ហើយមិត្តយើងត្រូវរៀបចំខ្លួនចេញដំណើរទៅ ។ រួចហើយសាមុតបាននាំកម្លាំងអស់ទំបាននេះមក  ពេលមកដល់ត្រពាំងថ្លាម  ឃើញកម្លាំងទាំងអស់ប្រហែលមួយអនុសេនាធំ  ហើយបងហួយបានមកអប់រំផ្ទាល់  គាត់បាននិយាយបំភាន់ថា  ឥឡូវនេះយើង ត្រូវទៅទីវ័យួននៅក្រុងទីព្រវែង  ព្រោះយួនចូលច្រើនណាស់ ។ រួចហើយបាននាំកងទ័ពចេញដំណើរទៅទាំងយប់  ពេលទៅជិតដល់សមរភូមិនេះឮសូរកាំភ្លើងគ្រប់កន្លែងនោះ ។ បន្ទាប់មកទៀតកងទ័ពអង្គការថា  កងទ័ពមកពីបូព៌ាមិនឱ្យចូលកន្លែងនេះជាដាច់ខាត  រួចហើយបងហួយក៏ខឹង  បាននាំកងទ័ពនេះដើរដាក់មីនបង្កប់តាម ផ្លូវថ្នល់ដែលអាចបើកឡានបាន  ដើម្បីបំផ្លាញកម្លាំងបដិវត្ត  កាលដែលដាក់មីន នៅកើតមានសភាពការណ៍នេះ  ធ្វើឱ្យសភាពច្របូកច្របល់  ដោយកម្លាំងទ័ពទីវ័ព្រាត់តែអ្នកជញ្ជូនគ្រាប់ត្រូវងាប់ជាបន្តបន្ទាប់ ។ ហើយឡានខ្លះត្រូវមីនខូចអស់ទៀតឯប្រជាជនក៏ងាប់អស់ច្រើន  ដោយសារតែជាន់មីនដែលពួកខ្ញុំដាក់ស្កាត់ផ្លូវកងទ័ពរបស់អង្គការ ។ ដូចេះផែនការដែលទៅជួយទប់ទល់អាភីមមិនបានសំរេច  ដោយកងទ័ពខ្ញុំ កងទ័ពអង្គការមិនឱ្យចូល ។ ដល់ក្រោយពីសំរេចផែនការនេះមិនបាន  បងហួយបាន

ឱ្យកងទ័ពរបស់ខ្ញុំដើរបំផុសប្រជាជន ឱ្យរត់ចូលព្រៃ ដោយបំផុសថាអង្គការចាប់អស់ហើយ តាំងពីថ្នាក់លើមកដល់ប្រជាជន ឥឡូវនេះទៀតអង្គការកំពុងតែចាប់ ដូចបងប្អូនឃើញស្រាប់ ល្អកាំភ្លើងនេះមិនមែនវីរ៍យួនទេ គឺអង្គការចាប់ប្រជាជ ននៅក្រុងព្រៃវែងម្ញាញ់ចោលទេ ។ ការបំផុសនេះធ្វើឱ្យប្រជាជនខ្លះក្ដាប់ការប្រែប្រួលមិនបានរត់ចូលព្រៃ ហើយសភាពនៅពេលនោះច្របូកច្របល់ខ្លាំងនៅក្នុងភូមិភាគទាំងមូល ។ ដល់ក្រោយពីចាប់អាភិមបានហើយ អង្គការបានចាត់តាំងអ្នកបដិវត្តត្រឹមត្រូវដើរឃោសនាប្រជាជនឱ្យគេប្រឆាំងអាភិម ដូច្នេះសភាពការ ណ៍តាំងពីស្ទះអាភិមមកធូរស្រាលបន្តិច ។ ប៉ុន្តែបក្សពួកខ្ញុំនៅតែបំផុសប្រជាជនឱ្យគាត់ច្របូកច្របល់ជាបន្តបន្ទាប់ហូរហែរមកដែរ ធ្វើម៉េចឱ្យបដិវត្តល្អុកល្អាញ ។ ដល់ខែ ៩ ឆ្នាំ ១៩៧៨នេះ បងហួយ បានហៅគ្រប់អនុសេនាធំ- វរៈសេនាតូចទៅប្រជុំ គាត់មិនហៅកម្លាំងរាត់ដូចមុនទៀតទេ ប៉ុន្តែក្រោយពីសភាពការអា ភិមមកកម្មាភិបាលខ្លះត្រូវគ្រាប់ទៅដេកពេទ្យអស់មួយចំនួន ហើយគាត់ហៅនេះមិនមែនហៅទាំងកម្មាភិបាលបដិវត្តទេ គឺគាត់ហៅកម្លាំងទៅប្រជុំ ការប្រជុំនេះអស់រយៈជិតកន្លះថ្ងៃ ទើបឃើញបងសាមុតមកអង្គភាពវិញ ។

ក្រោយមកបានពីរបីថ្ងៃ ទើបឃើញសាមុតបានហៅកម្លាំងមកប្រជុំ នៅកន្លែងអនុសេនាធំ មានឈ្មោះ សាវុន- រ៉ាន់- ឈន- មឿន- នី- ង៉ាង- ផាត-គៀ នថន- សារ៉ាន- ចិន- ស៊ុម- សារឿន ពេលនេះសាមុតបានលើករិះអង្គប្រជុំមានបញ្ហាទី២ដែលត្រូវអនុវត្តនៅក្នុងឆ្នាំនេះ :

១- ដំបូងខ្ញុំលើកឡើងអំពីសភាពការនៅក្នុងភូមិភាគសព្វថ្ងៃនេះ ឃើញថា

តាំងពីក្រោយផែនការបរាជ័យមក សភាពការយើងបច្ចុប្បន្ននេះល្អប្រសើរណាស់មិន មានបញ្ហាអីលំបាកទេ ការចាប់ចងឃើញធូរស្រាលជាងមុន ។ ដូច្នេះអង្គការ មិនចាប់អារម្មណ៍ទេពេលនេះទៅ ទទួលនៅក្នុងតំបន់យើងមិនទាន់ឃើញអង្គការនឹង ផង ។ បញ្ហាទី២ អំពីការធ្វើសកម្មភាពកន្លងមកយើងបានយកចិត្តទុកដាក់បាន នឹង អនុវត្តបានជាប់ ប៉ុន្តែនៅខ្វះខាតមួយចំណែកគឺ ការកសាងកម្លាំងក៏យើងនៅមិនបាន យកចិត្តទុកដាក់ម៉ែនទែនដែរ ដូចនេះការងារវាមិនដើរមកពីអញ្ចឹង ។

ក្រោយមកទៀតគាត់បានលើកបញ្ជាក់អំពីផែនការ សាមុតបានលើកថា ផែន ការឆ្នាំនេះតាមខ្ញុំទៅប្រជុំនៅមន្ទីរវិរៈសេនាធំ ដែលបងហួយគាត់លើកទៀង ថា ផែនការដែលយើងធ្វើបច្ចុប្បន្ននេះមិនបានទេ ពីដើមយើងគិតថាធ្វើពេលបុណ្យ ខួបបក្សដែរ ប៉ុន្តែបងហួយគាត់ថា ខ្លាចធ្វើទៅបរាជ័យដូចមុនទៀត នាំតែអង្គ ការនឹងទេ ហើយខូចខាតកម្លាំងមិនងាយកសាងទៀតទេ ហើយវាណានទៅរលំ រ លាយទៀតទាំងអស់ ។ បងហួយបន្តទៀតថា ចាប់ពីសភាពការណ៍មិនប្រែប្រួលក្នុង ពេលនេះទៅ គាត់ប្រាប់នៅគ្រប់អង្គភាពត្រូវខិតខំកសាងមនុស្សថ្មី ដែលជានុបក រណ៍របស់យើងឱ្យបាន ទាន់ពេលវេលានៅច្រើន ។ សាមុតបានលើកថាចាប់តាំងពី ឆ្នាំនេះទៅត្រូវកសាងកម្លាំងដោយសម្ងាត់ឱ្យបានច្រើនថែមទៀត កម្លាំងនេះ ត្រូវបង្កប់ឱ្យបានច្រើននៅគ្រប់អនុសេនាធំ នឹងនៅគ្រប់វិរៈសេនាតូច ។ ប៉ុន្តែ ពេលបច្ចុប្បន្ននេះបងហួយគាត់ថា ចាប់តាំងពីពេលនេះទៅមុខ ត្រូវឱ្យកម្លាំងអប់ រំបាននោះស្ងាត់ តែទិសសម្ងាត់ត្រូវធ្វើទៀត ហើយសកម្មភាព- បំផុសទំនាស់ យើង ត្រូវផ្អាក រៀបចំកម្លាំងដោយសម្ងាត់ម្តងវិញបានឈ្នះ ។ រួចហើយសាមុតបានលើក

ថា ចាប់ពីពេលនេះទៅ យើងត្រូវរៀបចំផែនការត្រៀមរដូវប្រាំងម្តងវិញម្តង ឯ ដើម្បីសម្រុបតាមបក្សយួនលើកឡើង ២ តាមបងហ្វួយគាត់មានផែនការថា : នៅក្នុងរដូវប្រាំងខាងមុខនេះត្រូវធ្វើរដ្ឋប្រហារវាយរំលំបក្សកុម្មុយកម្ពុជា ដោយរួមជាមួយយួននៅរដូវខាងមុខនេះ ។

បញ្ហាដែលត្រៀមពេលរដូវប្រាំងនេះ តាមបងហ្វួយលើកប្រាប់ខ្ញុំថា ចាប់ពេលនេះទៅមុខទៀត យើងត្រូវរៀបចំត្រៀមកាំភ្លើង ប៉ុន្តែកាំភ្លើងយើងមិនទាន់មានសំបូរបែបទេ តែយើងត្រូវត្រៀមរៀបចំឱ្យបានគ្រប់ដៃ នឹងបំពាក់ឱ្យយុទ្ធ-ជនណាដែលអាចអូសទាញបាន ឱ្យគេត្រៀមរៀបចំជាមួយយើងផង ។ ម្យ៉ាងទៀតគ្រាប់រំសេវ ចាប់ពីពេលនេះទៅ គ្រាប់រំសេវស.មមិត្តត្រូវយកចិត្តទុកដាក់សន្សំសំចៃឱ្យបានច្រើនទៀត យើងកុំពឹងតែគ្រាប់ខាងលើឱ្យពេក ត្រូវតែខំយកចិត្តទុកដាក់រៀបចំឱ្យបានច្រើនពីពេលនេះទៅ ។ ប៉ុន្តែដោយឡែកគ្រាប់រំសេវតាមបងហ្វួយថា គាត់បានត្រៀមទុកបានមួយចំនួនហើយ តែគាត់បានឱ្យតាមអង្គភាពត្រៀមរៀបចំទៀត ដើម្បីប្រមូលគ្នាឱ្យបានច្រើន សំរាប់សង្គ្រាមយូរអង្វែង ។ ក្រៅពីត្រៀមគ្រាប់រំសេវ នឹងកាំភ្លើង ត្រូវត្រៀមសេដ្ឋកិច្ចទៀតឱ្យបានសំបូរក្នុងការធ្វើសង្គ្រាមនេះ តាំងពីពេលនេះទៅ ពេលបើកអង្ករមកយើងត្រូវលួចទុកខ្លះ ដើម្បីសន្សំសំចៃទ្រព្យនេះទុក ។ តាមបងហ្វួយលើកប្រាប់ក្នុងអង្គប្រជុំថាអង្ករឆ្នាំ ១៩៧៨នេះត្រូវខ្វះផង ដោយសារមកពីទឹកជំនន់ពេលថ្មីៗនេះ ដូចនេះសេដ្ឋកិច្ចយើងខ្វះខាតផង មិនដូចឆ្នាំមុនៗទេ ឆ្នាំ ១៩៧៧ក៏ទ្រព្យសម្បត្តិអស់នេះសំបូរមិនដូចឥឡូវនេះទេ ទាល់តែស.មមិត្តត្រូវយកចិត្តទុកដាក់សន្សំសំចៃតាំងពី ឥឡូវ

នេះទៅទើបបានច្រើន ៗ ម្យ៉ាងទៀតបញ្ហាពេទ្យ បងហួយគាត់បានដាក់ថា នៅតាមកងអនុសេនាធំត្រូវមានពេទ្យពីរនាក់ទៅបីនាក់ ដើម្បីងាយស្រួលបំរើសមរភូមិ ពេលធ្វើរដ្ឋប្រហារនេះ ៗ ហើយពេទ្យនេះត្រូវទាមទាអ្នកប្រយុទ្ធលក្ខ ក្នុងការបំពេញភារៈកិច្ចប្រចាំសមរភូមិប្រយុទ្ធ ៗ

បន្ទាប់មកទៀតសាមុត បន្តទៀតថា ដើម្បីឱ្យសមស្របតាមផែនការនៅរដូវប្រាំងនេះ ខ្ញុំសូមមានយោបល់ដូចតទៅ ហើយស.មមិត្តត្រូវគិតគូរក្តាប់អនុវត្តឱ្យបានមត់-ចត់គឺ ពេលយើងធ្វើរដ្ឋប្រហារវាយទំលំបក្រុមឃ្មួយគីសនត្តជានៅរដូវប្រាំងនេះ ត្រូវចាត់តាំងកម្លាំងមួយចំនួនធ្វើសកម្មភាពដាច់ចំផុតដាច់ ធ្វើម៉េចឱ្យតែបដិវត្តស្មុគស្មាញដោះស្រាយពីរឿងយើងនេះនៅរដូវប្រាំងដែលយួនគេវ៉ៃចូល ៗ ប៉ុន្តែជាគន្លឹះ នៅរដូវនេះ ស.មមិត្តត្រូវក្តាប់បញ្ហាពីរឱ្យដាច់ ៖ ទីមួយត្រូវបំផុសនៅខាងក្នុងឱ្យប្រចូកប្រចល់ទៀង និងធ្វើសកម្មភាពអុកឡុកឱ្យដាច់ ៗ ទី២បញ្ហា គន្លឹះយើងត្រូវត្រៀមកម្លាំងវាយពីខាងក្នុងមុន ដើម្បីញែកចេញទៅត្រុំដែនបាន យួនគេជួយជំនួយដល់យើង ហើយរួមកម្លាំងគ្នាវ៉ៃតែម្តងនៅរដូវនេះឱ្យបានសំរេចតាមផែនការដែលខ្ញុំលើកទៀង ៗ អ្នកវាយពីក្នុងធ្វើយ៉ាងម៉េចត្រូវវាយឱ្យបានរហាស់ បំផុត បានទាន់ពេលវេលា ៗ អ្នកបំផុសប្រជាជនត្រូវបំភាន់ ធ្វើម៉េចឱ្យប្រជាជនទាំងអស់នោះមកខាងយើង ៗ ប៉ុន្តែផែនការវាយនេះ មិនមែនតែវាយនៅកន្លែងយើង ឬនៅក្នុងតំបន់យើង គឺនៅក្នុងភូមិភាគយើងទាំងមូល ហើយអាចឈានមកតាមភូមិភាគផ្សេងៗទៀតផង ប៉ុន្តែជាគន្លឹះនៅក្នុងតំបន់យើង និងនៅភូមិភាគយើងនេះត្រូវធ្វើដាច់ខាតអំពីផែនការនេះ បានសំរេចឬមិនបានសំរេចខ្ញុំថាមិនទាន់ សំ

ទៅទៀត ។ ហេតុនេះផែនការត្រូវតែមាន ហើយស.មមិនត្រូវធ្វើទើបសម្រេច តាមសំណូមពរអង្គប្រជុំលើក ។

## អំពីផែនការកំណត់វាយនិងមុខសញ្ញាថ្មី

ផែនការវាយទៅរដូវប្រាំងនេះ បងហួយ ដែលគាត់បានកំណត់ក្នុងអង្គប្រជុំថា ផែនវាយទៅឆ្នាំ ១៩៧៨នេះ តែវាយទៅក្នុងឆ្នាំ៧៨នេះមិនបាន យើងត្រូវមានផែនការតទៅមុខទៀតគឺដើមឆ្នាំ ១៩៧៩ និងឆ្នាំទៅទៀត ដូច្នេះផែនការត្រៀមមិនចេះរលត់មិនចេះរលាយ ត្រូវត្រៀមជាប់ និងកសាងកម្លាំងឱ្យបានជាប់ បើកម្លាំងច្រើនយើងវាយបានរហាស់ ឈ្នះរហាស់ទៀត ។ សាមុតបន្តទៀតថា ផែនការបងហួយបានលើកឡើងថាទិសការងារនេះត្រូវអនុវត្តឱ្យបានសំរេច បើមិនបានសំរេចក្រែងតែអង្គការចាប់ និងមានវិធានការមុន ទើបឈប់ ឈប់គ្រាន់តែផ្អាកបន្តិចចាំរងមើលសភាពការណ៍ ។ តែកម្លាំងត្រូវត្រៀមរៀបចំជាប់ទៅគ្រប់ អនុសេនាធំទាំងអស់នេះមួយផ្នែកក្នុងផែនការវាយ ។

បញ្ហាមុខសញ្ញាដែលត្រូវវាយទៅក្នុងឆ្នាំ១៩៧៨.១៩៧៩នេះគឺ បងហួយ បានលើកផែនការថា ឥឡូវនេះខ្ញុំគ្រាន់តែលើកមុខសញ្ញារបស់យើងទេ ហើយគ្រាន់តែលើកទៅក្នុងវរៈសេនាធំយើងនេះ បងហួយដាក់ថា វរៈសេនាធំយើងនេះត្រូវក្ដាប់ទិសវាយគឺ : នៅស្រុកកោះជ័យ និងស្រុកតាមជរ ទាំងពីស្រុកនេះមានវរៈសេនាធំគេផ្សេងទេ ប៉ុន្តែផែនការគោលកំណត់ដូចគ្នាទាំងអស់ នេះមួយមុខសញ្ញា នៅស្រុកត្របែកមុខសញ្ញាវរៈសេនាធំរបស់ខ្ញុំ គឺបើកដៃឱ្យពួនចូលរដូវនេះមានមុខសញ្ញាដូចតទៅ : នៅចន្លាយក្រយ៉ាង- ត្រពាំងព្រាម មុខសញ្ញានេះបើពួនគេ-

ចូល យើងត្រូវបើកមុខសញ្ញានេះ ព្រោះអីមុខសញ្ញានេះធំ វាយបានរហ័ស ។ ហើយទិសសំខាន់ដែលយើងត្រូវវ៉ៃយក គឺកងទ័ពយើងពីតំបន់ ២៥ នេះត្រូវវាយយ៉ាងម៉េចឱ្យដល់នាក់លឿង ឯក្រៅពីនេះនៅតាមតំបន់ផ្សេងៗគេវាយមកយកនាក់លឿងដាច់ខាតដែរ ហើយបញ្ជាការសមរភូមិស្រុកតំបន់ត្រង់បកនេះមានបង ហួយ- បងសារឹម គាត់ជាអ្នកទទួលខុសត្រូវផ្ទាល់ ។ ជាគន្លឹះនៃផែនការនេះគឺយើងវាយយកនាក់លឿង ក្រៅពីនេះទៀតតាមដងទន្លេមេគង្គ ព្រោះកន្លែងនេះសំខាន់ក្នុងការយួនដឹងជញ្ជូនស្បៀង និងសំភារៈទៀត ។

ក្រៅពីនេះទៀត យើងត្រូវមានផែនការទាក់ទងយួនទៀត ការទាក់-ទងយួន ដូចបានចាត់តាំងពីខែមុនអញ្ចឹង មិនកែប្រែទេ ។ សាមុតបន្តទៀត ថាកងទ័ពយើងត្រៀមនេះមិនមែនទៅវ៉ៃក្នុងដីយួនមកទេ គឺដល់ពេលយួនគេផ្ទុះភ្លាមមកកម្លាំងយើងត្រូវវ៉ៃខាងក្នុងជាគន្លឹះ យើងឱ្យប្រជាជនច្របូកច្របល់ ដូច្នេះវ៉ៃបានជ័យជំនះទៀត ពេលនេះយើងពិតជាសំរេចបានហើយ ។ រួចហើយសាមុតបានសួរ មតិអង្គប្រជុំអំពីផែនការនេះយ៉ាងម៉េច មតិអង្គប្រជុំមានសេចក្ដីយល់ស្រប និងអនុវត្តនៅផែនការថ្មីនេះ ។ រួចហើយក៏បែកគ្នាទៅតាមកន្លែងរៀងៗខ្លួន ខ្ញុំក៏បានមកកន្លែងវិញដែរ ពេលមកដល់ដំបូងខ្ញុំមិនទាន់បានធ្វើអីទេ ។ ដល់ខែ១០៧៨ អង្គការបានលើកផែនការវ៉ៃទៅសមរភូមិ ពេលនេះអង្គការបានរើសក្នុងមួយអនុសេនាធំយកបួនពួកទៅវ៉ៃនៅសមរភូមិនេះ ក្នុងនេះខ្ញុំបានទៅដែរ ។ ពេលវ៉ៃសមរភូមិនេះអង្គការត្រូវឱ្យចូលវ៉ៃនៅវេលាម៉ោង ១យប់ ពេលវ៉ៃនេះនៅថ្ងៃទី ១២. ១០.១៩៧៨ នេះវ៉ៃនៅសមរភូមិ ។ ក្រោយពីចាត់តាំងកម្លាំងនេះហើយបានប្រ

ជា២ថ្ងៃ ដល់ផែនការទីរីយ៉ូននៅសមរភូមិនេះ ពេលនោះខ្ញុំត្រូវទៅរៀនផែន ការចាប់ទីរ៉ែតាំងពីម៉ោង ១យប់ ដល់ម៉ោង ៥ជិតភ្លឺ ខ្ញុំត្រូវរបួស ហើយមិត្តយើងយក នៅខាងក្រោយ ។ ហើយក៏បានមកដេកពេទ្យនៅភ្នំពេញ ជាដំបូងខ្ញុំដេកនៅ ពេទ្យ ១៧ ខ្ញុំបានជួបគ្នាខ្ញុំម្នាក់ឈ្មោះ សុន ដែលជាខ្សែចាស់របស់ខ្ញុំ ប៉ុន្តែមិនបានមក ជួបគ្នាទេ ព្រោះពេទ្យដាក់នៅដោយឡែក ខ្ញុំនៅអាគារផ្សេង សុន នៅ អាគារផ្សេង ។ ដល់ថ្ងៃទី ២៨.១០.១៩៧៨ ពេទ្យត្រូវបញ្ជូនខ្ញុំទៅពេទ្យ ៦ មករាទៀត ពេលមកដល់នេះខ្ញុំជួបខ្សែរបស់ខ្ញុំម្នាក់ទៀតឈ្មោះ វង់ ប៉ុន្តែវង់នៅ ពេទ្យគេកំពុងវះ ដូច្នេះមិនបានចូលទៅសួរទេ គ្រាន់តែថ្ងៃខ្ញុំឱលរ្យាហ៊ីរដើរ មើល គាត់ក្រែងបានពិភាក្សាគ្នា ដល់ខ្ញុំទៅពេទ្យមិនឱយចូលទៀត ។ ដល់ថ្ងៃទី ១.១១ ឆ្នាំ ១៩៧៨នេះ ពេទ្យត្រូវបញ្ជូនខ្ញុំពីមន្ទីរពេទ្យ៦ មករា ទៅនៅកន្លែង តាខ្មៅ ពេលទៅដល់ដំបូងខ្ញុំបានជួបឈ្មោះ សុន យុទ្ធជននៅយោធាតំបន់២៥ជាមួយខ្ញុំ ។ ពី ជាប្រធានអនុសេនាតូច ។ វាំជាប្រធានក្រុម ទាំងបីនាក់នេះសុទ្ធតែខ្សែ របស់ខ្ញុំមកពីបូព៌ាទាំងអស់ ដល់ខ្ញុំមកនៅបានមួយថ្ងៃ ទើបពីបានហៅពួកខ្ញុំទាំងបី នាក់ នេះប្រជុំនៅលើផ្ទះថ្មសម្ងាត់ ហើយគ្មានពីណាដឹងទេ ពេលនោះពីបាននិយាយថា : យើងមកនៅកន្លែងនេះមានគ្នាតែ ៥នាក់អញ្ចឹង ហើយផែនការរបស់យើងដែលគេ ធ្វើនៅខាងណោះមិនដឹងយ៉ាងណាទេ បើយើងនៅកន្លែងនេះយូរ ប្រាកដជាដាច់ខ្សែ ទាក់ទង ហើយផែនការអីក៏ដាច់ដែរ ។ បើនៅកន្លែងយើងណោះបានបន្តទៀត ដល់មកនៅកន្លែងនេះគ្នាក៏តិច ដូចនេះដាច់ ។ ហើយនៅក្នុងចំណោមនេះគ្មាន អ្នកមកពីបូព៌ាឯណាច្រើនទេ មានសុទ្ធតែភូមិភាគគេផ្សេងៗ ពេលនេះយើងមិនងាយ

កលាងបានទេ ៗ ធី បានបន្តទៀតថា ទោះយ៉ាងណាក៏ដោយ ឱយតែយើងអាចទាក់ទងបាន មិនចាំបាច់តែខ្មែរមកពីភូមិភាគបូព៌ាទេ នៅភូមិភាគផ្សេងទៀត ក៏អាចយើងទាក់ទងបានដែរ ព្រោះចិត្តមនុស្សមិនមែនដូចគ្នាទេ ដូច្នេះយើង ត្រូវតែចំកលាងកម្លាំងនៅក្នុងនេះទៀតឱយបានច្រើន ៗ រួចហើយធីបានលើកផែនការឱយទាក់ទងគឺ : ចាប់ពីពេលនេះទៅ យើងត្រូវដើរទាក់ទងនៅតាមកន្លែងនិមួយៗឱយបានគ្រប់ ពិសេសនៅកន្លែងរោងចក្រធ្វើមង យើងត្រូវទៅពិនិត្យ មើលតើមានអ្នកមកពីភូមិភាគបូព៌ាទេ ក្រែងមានជួបខ្មែរយើងទៀត ងាយយើងទាក់ទងទៀត កុំឱយវាដាច់ខ្សែ ៗ មួយទៀតពាក្យបំផុសត្រូវតែអនុវត្តឱយបានជាប់ទាន់តែមានបំផុស នឹងធ្វើសកម្មភាពខ្លះ ទើបកលាងកម្លាំងបានឆាប់ រួចហើយក៏បែកគ្នាទៅ ៗ ក្រោយពីបាននិយាយពិភាក្សាគ្នាហើយ ក្រោយមកបានប្រហែលជា១ថ្ងៃ ធី - សុន - វ៉ា បាននាំខ្ញុំទៅទាក់ទងនារីម្នាក់នៅដាំបន្លែ នារីនេះ នៅស្រុកជាមួយ សុន ហើយស្គាល់គ្នាផង ៗ ពេលខ្ញុំទៅទាក់ទងនារីនេះគាត់កំពុង ធ្វើដីដាំបន្លែ នឹងនារីនៅក្នុងនោះពីរបីនាក់ទៀត ប៉ុន្តែគេនៅឆ្ងាយពីនារីនេះ ពេលពួកខ្ញុំចូលទៅដល់ នារីនោះស្គាល់មិត្តសុន គាត់បានរត់មកចាប់ដៃមិត្តសុន ហើយគាត់សួរមិត្តសុនថា មិត្តមកពីណាដែរ បានដល់កន្លែងនេះ សុនឆ្លើយប្រាប់គាត់ថា ខ្ញុំត្រូវរបួស ហើយមកដេកពេទ្យ ដល់ខ្ញុំជាអង្គការបញ្ជូនមកកន្លែងនេះ ដល់និយាយបានត្រឹមនឹង អ្នកដែលគេនៅមុនបានរត់មកប្រាប់ពួកខ្ញុំទាំង២នាក់ថា កុំទៅនិយាយជាមួយគាត់ច្រើនពេក គាត់មកកន្លែងនេះដោយសារគាត់ពាក់ពាន់ទេ បានដកគាត់មកពីរោងចក្រ នាំតែមិនសមផ្គួនមហាជនជិតខាងទេ ៗ បន្ទាប់ពីយុទ្ធជននោះ

ប្រាប់ហើយ ធីបានថាឱ្យយុទ្ធជននោះថា កុំពីណាចាប់គេ គ្រាន់តែនិយាយលេងមិន
បាន យុទ្ធជននោះក៏បានដើរចេញទៅ ។ ហើយពួកខ្ញុំបានទៅទាក់ទងនារីនោះ
ទៀត ពេលនោះធីបានសួរនារីនេះថា បងឯងពីដើមនៅកន្លែងណា នារីប្រាប់
ថា ខ្ញុំពេលមុនមកនេះ គឺនៅរោងចក្រធ្វើមង ធីសួរបន្តទៀត ម៉េចបានជាបង
មកនៅកន្លែងនេះ ពេលនោះនារីមិនហ៊ានឆ្លើយ ទាល់តែយូរបន្តិច ដោយសារពី
ពួកខ្ញុំសួរញឹកពេក នារីនេះទើបប្រាប់ថា ខ្ញុំមានការពាក់ពាន់ខាងពីនៅស្រុកមក
ម្លេះ ដល់អញ្ចឹងអង្គការដកខ្ញុំឱ្យមកនៅកន្លែងនេះ ។ រួចហើយក៏បានបែកគ្នា ។
ដល់ក្រោយមកទៀតសុនបានប្រាប់ខ្ញុំថា កាលដែលចេញពីនោះមក ខ្ញុំបានខុសសីលធម៌
ជាមួយនារីនោះហើយ ដូច្នេះយើងទៅទាក់ទងទៀត ដល់ក្រោយមកបានប្រហែល
ជា ៥ថ្ងៃ ខ្ញុំ- ធី - សុន - រ៉ា បានទៅទាក់ទងនារីនៅកន្លែងនឹងទៀត ពេលពួក
ខ្ញុំទៅដល់មិនទាន់បានសួរគាត់ផង ស្រាប់គាត់សួរមកពួកខ្ញុំថា ម៉េចទៅមិត្តសភាពការ
ណ៍នៅភូមិភាគយើងយ៉ាងម៉េច ពិសេសនៅស្រុកភូមិយើងបច្ចុប្បន្ននេះ ធី - សុនបាន
ឆ្លើយប្រាប់គាត់ថា កាលពីឆ្នាំ ១៩៧៨ដើមឆ្នាំសភាពការប្រែប្រួលច្រើនដែរ ។
មួយការចាប់ចងច្រើន ហើយសភាពប្រជាជនក៏លំបាក តែដល់ឥឡូវនេះមិនសូវទេ។
នារីនេះបាននិយាយម្ដងទៀតថា អញ្ចឹងហើយបានជានារីនៅរោងចក្រកាលពេលនឹង
ឃើញតែអង្គការដក ពិសេសនារីមកពីភូមិភាគបូព៌ាយើងឃើញតែអង្គការដក ហើយ
រួចខ្ញុំក៏អង្គការដកដែរ ។ ក្រោយពីដឹងចំណុចខ្សោយរបស់គាត់អញ្ចឹងហើយ ពួកខ្ញុំ
បាននិយាយអប់រំគាត់តែម្ដង ដោយពួកខ្ញុំក្ដាប់បានគាត់ស្រាប់ ម្យ៉ាងទៀតគាត់ធ្លាប់
ប៉ះពាល់ផ្នែកសីលធម៌ហើយ ដល់ក្រោយគាត់សុខចិត្តចូលបំរើមក ធីបានណែនាំឱ្យគាត់-

ជួយទាក់ទងយុទ្ធជនដែលពេទ្យបញ្ជូនមកដាក់កន្លែងនេះ ពិសេសយុទ្ធជនដែលមកពីបូព៌ា ធ្វើម៉េចចំកសាងកម្លាំងឱ្យបានច្រើន ។ មួយទៀតឱ្យគាត់ធ្វើសកម្មភាពបផ្លិចបំផ្លាញទ្រព្យសម្បត្តិកន្លែងនេះទៀត ហើយដំណាំនៅកន្លែងបងដាំត្រូវបផ្លិចបំផ្លាញទៅៗ រួចហើយក៏បែកគ្នាទៅ ។ ក្រោយមកពីបីថ្ងៃទៀត ក៏ពួកខ្ញុំបានទាក់ទងខូចសីលធម៌ជាបន្តបន្ទាប់ ទាំងខ្ញុំ ទាំងកម្លាំងរបស់ខ្ញុំ ។ ហើយពួកខ្ញុំនៅទីនោះពេលយប់បង្កិចគ្មានធ្វើអីទេ ដើរតែបំផ្លាញដំណាំពេទ្យ ដូចជាឪស្លពួកខ្ញុំយកកូនកាំបិតទៅកាត់គល់ ហើយដំណាំផ្សេងទៀតក៏ពួកខ្ញុំបំផ្លាញអស់ច្រើនដែរនៅទីនោះ ។ មុនពេលដែលពេទ្យត្រូវបញ្ជូនខ្ញុំមកកន្លែងផ្សេងទៀត ខ្ញុំ- ធី- រ៉ា- សុន បាននាំគ្នាទៅរកខ្សែទាក់ទងរោងចក្រមងទៀត ពេលចេញទៅតាមផ្លូវត្រូវពេទ្យឃាត់មិនឱ្យទៅ ហើយនាំគ្នាត្រឡប់មកកន្លែងវិញ ។

ដល់ថ្ងៃទី ១៧. ១១.១៩៧៨នេះ ពេទ្យត្រូវបញ្ជូនពួកខ្ញុំទៅនៅកន្លែង កប់ស្រូវ ប៉ុន្តែបញ្ជូនពីនេះទៅយប់ ហើយឱ្យសំរាកនៅកន្លែងនីរសាក្រុងអស់មួយយប់ ។ ដល់ព្រឹកឡើងក្នុងថ្ងៃទី ១៨.១១.១៩៧៨អង្គការបានបញ្ជូនពួកខ្ញុំមកនៅកន្លែងកប់ស្រូវជិតពោធិចិនតុងវិញ ។ " ខ្ញុំសូមបញ្ជាក់ថា នារីនេះខ្ញុំភ្លេចឈ្មោះហើយមិនចាំទេ ប៉ុន្តែរៀងនៅខ្ញុំចាំទាំងអស់ មុខមូលមានអីទេកុតពុមុខចង្អិច - សក់វែងក្រញាញ់បន្តិច - សំបុរខ្មៅស្រអែម - មាឌគាត់ ខ្ពស់ក៏មិនខ្ពស់ប៉ុន្មានទេរៀងល្មម- បច្ចុប្បន្ន ជាយុទ្ធនារីដកពីរោងចក្រ នៅកន្លែងដាំបន្លែតាខ្មៅ " ។ ពេលមកដល់កន្លែងកប់ស្រូវបានបានមួយព្រឹក ហើយគេត្រូវទៅធ្វើការងារចាំងស្មៅ - ពេលនោះខ្ញុំ- ធី- រ៉ា- សុនបានទៅធ្វើការងារនឹងគេដែរ ពេលចាំងនេះតាំង

ពីព្រឹកមកម្លេះ ខ្ញុំមិនទាន់ស្គាល់អ្នកណាមួយទេ ស្គាល់តែអ្នកមកពីភូមិភាគដែលជាខ្សែរបស់ខ្ញុំទៅពីតាខ្មៅនេះទៅ ។

ពេលប្រហែលជាថ្ងៃត្រង់ នៅក្នុងថ្ងៃទី ១៨.១១.៧៨ ខ្ញុំបានជួបជាមួយកម្លាំង ខ្ញុំឈ្មោះ វ៉ុន កាលនៅកងពលតំបន់ ២៤ ជាប្រធានអនុសេនាធំ បច្ចុប្បន្ននេះ នៅកន្លែងកប់ស្រូវទទួលនាទីជាប្រធានអនុសេនាធំដែរ ។ យ៉ន កាលនៅកងពលតំបន់-២៤ ប្រធានក្រុម នាទីបច្ចុប្បន្នក្តាប់មិនទាន់បាន ។ វឿន ប្រធានក្រុម កាលនៅយោធាតំបន់២៤ បច្ចុប្បន្នក្តាប់មិនបានទេ ។ យិន ជាយុទ្ធជន - ហើយនិង ពួកខ្ញុំមកពីតាខ្មៅ ៤នាក់ទៀតគឺឈ្មោះ ធី- សុន- រ៉ា- ខ្ញុំ បងវ៉ុនថា ចាំដល់ពេលល្ងាចបាយហើយ មកប្រជុំគ្នាបន្តិចនៅក្រោមផ្ទះជិតកន្លែងដាំស្លនេះ រួចហើយ ក៏បែកគ្នាទៅធ្វើការរៀងៗខ្លួនវិញ ។

ដល់ពេលល្ងាចម៉ោង ៧ល្ងាច វ៉ុន បានហៅកម្លាំងទាំងអស់មកប្រជុំមានផែនការធ្វើនៅកន្លែងនេះទៀត អ្នកចូលរួមប្រជុំមានឈ្មោះ យ៉ន- វឿន- យិន- សុន រ៉ា- ធី- ខ្ញុំ- វ៉ុន បានលើកឡើងថា ស.មមិត្តយើងមកនៅកន្លែងនេះច្បាស់ជាមិនបានទៅអង្គភាពវិញទេ ព្រោះអីទាំងអ្នកមកមុនគេប្រាប់ខ្ញុំថា ឱយតែ អ្នកមកដល់កន្លែងនេះមិនបានទៅអង្គភាពចាស់វិញ ត្រូវអង្គការរៀបចំអង្គភាពថ្មីហើយ អង្គភាពថ្មីនេះ អង្គការបញ្ជូនទៅកំពង់ឆ្នាំង ដូចនេះផែនការ និងការមកពីណុះ ត្រូវផាច់ខ្សែទាក់ទង ។ វ៉ុនបន្តទៀតថា យើងនៅកន្លែងនេះមិនដឹងទៅទីពឹងអ្នកណា ព្រោះយើងមិនទាន់ស្គាល់ភូមិសាស្ត្រច្បាស់ផង ប៉ុន្តែស.មមិត្តទាំងអស់ ត្រូវតែខិតខំសួរគេឯងឱយស្គាល់ភូមិសាស្ត្រនិងទឹកដីកន្លែងនេះឱយបានច្បាស់ ។ រួចហើយ

វ៉ុន បានសួរខ្ញុំថា អ្នកបួសមកដកពេទ្យក្រោយគេ ពេលអ្នកទាំងអស់ឆ្លើយថា ខ្ញុំមកដកពេទ្យក្រោយគេ ពេលនេះវ៉ុនបានសួរខ្ញុំថា ម៉េចសភាពការណ៍នៅក្នុងអង្គភាពយោធាយើងកាលមិត្តនៅឯណោះយ៉ាងម៉េច ខ្ញុំបានឆ្លើយប្រាប់គាត់វិញថា កាលដែលខ្ញុំនៅអង្គភាព ផែនការពេលថ្មីៗនេះគេកំពុងរៀបចំហើយ ពិសេសផែនការធ្វើនៅរដូវប្រាំងនេះ អង្គភាពយើងកំពុងរៀបចំគ្រាប់រំសេវ - កាំភ្លើង - ស្បៀងអាហារ និងសំភារៈផ្សេងៗទៀត ហើយផែនការកំណត់នៅពេលឆាប់នេះ ។ វ៉ុន បានសួរខ្ញុំថា ម៉េចស.មមិត្តសភាពការណ៍ប្រែប្រួលដូចមុនទេ លើការចាប់ចងសព្វថ្ងៃ ៖ ខ្ញុំឆ្លើយប្រាប់គាត់ថា នៅក្នុងចុងឆ្នាំ ១៩៧៨នេះការចាប់ចងនៅក្នុងតំបន់-និងនៅក្នុងអង្គភាពយោធាយើងមិនមានអីប្រែប្រួលដូចមុនទេ ប៉ុន្តែសព្វថ្ងៃ កំពុងតែអនុវត្តទៀត នៅពេលសភាពការណ៍មិនប្រែប្រួលនេះ ដើម្បីសំរេច ផែនការនៅឆ្នាំ ១៩៧៨.១៩៧៩នេះ ។ ខ្ញុំបន្តទៀតថា សព្វថ្ងៃនេះសភាពស្ងាត់តែក្រៅទេ តែថ្ងៃក្នុងគឺ បក្សពួកយើងកំពុងត្រៀមរៀបចំផែនការញឹកញាប់ណាស់ដែរ ដើម្បីបំរើផែនការពេលរដូវប្រាំងនេះ ។

ក្រោយពីខ្ញុំលើកប្រាប់គាត់អស់ហើយ វ៉ុនបានដាក់ផែនការធ្វើនៅកន្លែងនេះក្នុងការប្រមូលកម្លាំង វ៉ុនបាននិយាយថា យើងកម្លាំងដែលរក្សាបានតាំងពីយូរហើយបណ្តឹងពេលនេះត្រូវរក្សាកម្លាំងនេះឱ្យគត់មត់ថែមទៀត ។ វ៉ុនបន្តថា ខ្ញុំមកនៅ ទីនេះបានត្រូវអង្គការចាត់តាំងជាប្រធានអនុសេនាធំទៀត ដូច្នេះស.មមិត្តត្រូវជួយការពារឥទ្ធិពលរបស់យើងឱ្យបានជាប់ ដើម្បីកសាងកម្លាំងឱ្យបានច្រើនទៀត ។ ឥឡូវនេះយើងម្នាក់ធ្វើម៉េចគិតខំប្រមូលកម្លាំងពួកយើងដែលមកពីបូព៌ាឱ្យបានឆាប់រហ័ស

ដើម្បីយើងរៀបចំធ្វើរដ្ឋប្រហានឹងគេដែរ ហើយពួកយើងមកពីបូព៌ានៅកន្លែងនេះ ក៏ច្រើនដែរ ។ ក្រៅពីការត្រៀមប្រមូលកម្លាំងនេះ យើងត្រូវមានផែនការទៀត គឺទាក់ទងនៅក្នុងអង្គភាពនេះ នឹងចេញក្រៅអង្គភាពនេះទៀតឱ្យបានមមាញឹកដែរ ធ្វើម៉េចចាប់ពីពេលនេះទៅត្រូវខិតខំរកវិធីកសាងកម្លាំងឱ្យបាន ។ បន្ទាប់មកទៀត យើងនៅជិតទីក្រុងភ្នំពេញផង កន្លែងអង្គការក៏នៅទីនេះដែរ តាំងពីពេលនេះទៅខ្ញុំត្រូវចាត់តាំងកម្លាំងខ្លះដើរស៊ើបការ នឹងទាក់ទងនៅតាមទីក្រុងរកកម្លាំងមកពីបូព៌ាទៀត ។ ដោយឡែកបញ្ហាស៊ើបការរឿងនេះ សំខាន់ណាស់ បើឃើញកន្លែងសំខាន់ៗ ហើយនឹងកន្លែងអង្គការល.មមិត្តណាដែលទទួលភារកិច្ចខាងស៊ើបការនេះ ត្រូវគូសផ្លូវឱ្យបានល្អិតពីកន្លែងណាទៅកន្លែងណា បើមិនដឹងកន្លែងនេះត្រូវលួចសួរគេ ដោយលក្ខការណ៍បំផុត ហើយពិនិត្យសភាពការណ៍ឱ្យ បានច្បាស់នៅទីតាំងដែលអង្គការបោះនៅ យើងយកកន្លែងអ្វីដែលអាចកត់សំគាល់បាន ល្អក្នុងការចាំច្បាស់ទីកន្លែងនោះ ។ ក្នុងការក្លែងខ្លួនដើរស៊ើបការនៅក្នុងទីក្រុងតាមធម្មតាយើងត្រូវតែមានស្បៀងក្លែងមួយ ដើម្បីធ្វើដូចជាអ្នកដើរតខ្សែទូរស័ព្ទនេះ តាមខ្ញុំនៅមន្ទីរពេទ្យធ្លាប់ឃើញគេដើរតខ្សែទូរស័ព្ទ បើយើងធ្វើអញ្ចឹងទៅអាចចូលបាន ហើយបន្លំខ្លួនបានទៀត ព្រោះគេមិនសូវចាប់អារម្មណ៍យើងដែរទេ ។ ការចេញដំណើរពីទីនេះទៅ យើងត្រូវរក្សាគោលជំហររាបសារបដិវត្តជានិច្ចកុំគេសុំឆែកយើងទៅសំឡុតគេ ឬមួយស្ដីឱ្យគេប្រយ័ត្ន បើគេសួរសុំឆែកក្ដី ត្រូវឆ្លើយ-ចេញពីពេទ្យទៅអង្គភាពវិញ ឬទៅលេងបងប្អូននៅកន្លែងអីកន្លែងស្រេចតែមិត្តយើងទទួលខុសត្រូវមុខបញ្ហានេះដោះស្រាយទេ ។ ចុះតែបើដើរតាមផ្លូវគេសួរ

យើងត្រូវឆ្លើយថា ខ្ញុំដើរតែខ្សែទូរស័ព្ទនេះ យើងអាចដោះស្រាយរួចមួយគ្រា ។ ដូចនេះផែនការនេះខ្ញុំគ្រាន់តែគ្រោងរៀបចំបំភ្លឺមិត្តយើងទេ ឱ្យដឹង ចាំមើលបន្តិចខ្ញុំចាត់តាំងអ្នកណា ត្រូវអនុវត្តឱ្យបានសំរេចផែនការនេះ ។ រួចហើយក៏បែប-គ្នាទៅ ។ ដល់ថ្ងៃទី ១៩.១១.១៩៧៨នេះ វ៉ុនបានហៅខ្ញុំទៅកន្លែងគាត់ម្តងទៀត ពេលខ្ញុំទៅដល់ឃើញឈ្មោះ លុន - ធី ពេលនេះគាត់ត្រូវចាត់តាំងខ្ញុំឱ្យដើរយកការនៅទីក្រុងភ្នំពេញជាលើកទី១ : ពេលដែលគាត់ឱ្យខ្ញុំមកយកការគាត់បាន ណែនាំថា ឥឡូវនេះខ្ញុំត្រូវចាត់តាំងស.មមិត្ត វី មកយកការណ៍នៅទីក្រុងភ្នំពេញហើយ វ៉ុន បានណែនាំខ្ញុំថា ពេលមិត្តទៅយកការនេះត្រូវធ្វើយ៉ាងម៉េចទទួលខុសត្រូវភារៈកិច្ចនេះឱ្យបានខ្ពស់ នឹងទទួលខុសត្រូវចំពោះផែនការ ។ វ៉ុន បន្តទៀតថាមិត្តវីឯងបំពេញភារៈកិច្ចនេះបាន មិត្តត្រូវមករាយការណ៍ប្រាប់ខ្ញុំ បើមករាយការប្រាប់ខ្ញុំមិនរួច ឬលំបាកខាងដើរដោយគេចាប់ឬយ៉ាងណា ស.មមិត្តត្រូវរត់ចេញពីទី ក្រុងនេះដោយស្ងាត់ វិលត្រឡប់ទៅអង្គភាពវិញ ។ ប៉ុន្តែស.មមិត្តមុននឹងរត់ចេញមកអង្គភាពវិញត្រូវគូសផ្លូវ ហើយធ្វើជាផែនទីយកការណ៍ឱ្យបានច្បាស់ដូចខ្ញុំបានប្រាប់ៗកាលពីប្រជុំមុនអញ្ចឹង ។ ហើយក្នុងការស៊ើបការនេះតាមស.មមិត្តធ្វើបានព្រោះខ្ញុំបានប្រាប់រួចមកហើយ ។ រួចហើយវ៉ុន បានបញ្ជាក់ប្រាប់ខ្ញុំថា ពេលដែលយើងដើរទៅត្រូវចាក់ទងគេមើល ហើយសួររកមើលអ្នកមកពីភូមិភាគយើងនៅទីណាច្រើនជាងគេ ហើយស.មមិត្តត្រូវរកវិធីទាក់ទង បើគេសួរដេញដើងយើងក្នុងការសួរ អ្នកមកពីភូមិភាគបូព៌ា យើងត្រូវឆ្លើយរកបងប្អូនឬរកធ្វើជំនួញទៀតទៅតាមលទ្ធភាពស.មមិត្តអាចធ្វើបានរបស់ខ្លួនយើង ។ ពិសេសអ្នកមកពីភូមិភាគយើងច្រើននៅតាមផ្សារ

ក្រសួង ហើយខ្លះទៀតអាចទៅតាមរោងចក្រផង ដូចនេះពេលដែលមិត្តដើរមក ត្រូវសាកសួរគេឱ្យបានច្បាស់លាស់ផង ។ មុនពេលចែកគ្នាចេញមកយកការណ៍ វ៉ុន បានប្រាប់ខ្ញុំថា ស.មមិត្តត្រូវចេញពីនេះទៅ មិត្តត្រូវទាក់ទងមិត្ត វង់ នៅមន្ទីរពេទ្យ៦មករា ព្រោះគាត់ដេកពេទ្យនៅកន្លែងនេះស្រាប់ ។ ខ្ញុំបញ្ជាក់វង់នេះជាខ្មែររបស់ខ្ញុំមកពីអង្គភាពផង ប៉ុន្តែគាត់ទៅដេកពេទ្យ ៦ មករា ។ មិត្តត្រូវសាកសួរគាត់មើល តើមានកម្លាំងមកពីកន្លែងយើងមានទៀតទេ ដើម្បីឱ្យដឹងផង ។ រួចហើយក៏ចែកគ្នា ខ្ញុំបានរៀបចំស្បៀងក្លួមមួយស្ពាយ ដើម្បីក្លែងខ្លួនតាមទុំប្រាប់ ក៏បានធ្វើដំណើរមកតាមផ្លូវថ្នល់ប្រឡាយ ហើយខ្ញុំដើរកាត់តាមប្រឡាយនេះត្រង់មកកើត ហើយបានជួបថ្នល់ក្រាល~~កៅ~~ថ្មអាចបើកឡានបាន ពេលនោះមិនបានជួបអ្នកណាទេ ហើយខ្ញុំបន្តដំណើរតាមថ្នល់នេះត្រង់មកត្បូង ហើយបានមកដល់ថ្នល់ រទេះភ្លើងបានជួបអ្នកយាមពីរនាក់សុទ្ធតែនារី ពេលនោះខ្ញុំមិនហ៊ានសួរទាក់ទងគេទេ ព្រោះអីគេយាមខ្លាចចាប់ខ្ញុំ ក៏ដើរចៀសពីកន្លែងយាមបន្តិចចូលថ្នល់ដដែល ហើយនារីយាមពីរនាក់ក៏អត់សួរខ្ញុំដែរ ។ ចាប់ពីនោះមកទៀតខ្ញុំបានបន្តដំណើរមកតាមថ្នល់នេះទៀត ដើរបានបន្តិចខ្ញុំត្រូវបែកចូលថ្នល់ជាតិក្រាលកៅស៊ូម្តង ហើយបានដើរដដែរត្រង់មកកើត ពេលដែលបែកចូលនេះ ខ្ញុំបានសួរនារីពីរនាក់ដែលដើរតាម ថ្នល់ថា បងរោងចក្រនេះធ្វើអី នារីឆ្លើយប្រាប់ខ្ញុំថា រោងចក្រនេះជារោង - ចក្រតម្បាញ ខ្ញុំបានសួរនារីនេះទៀតថា រោងចក្រនេះមានអ្នកមកពីភូមិភាគបូព៌ាទេបង នារីឆ្លើយប្រាប់ខ្ញុំថា រោងចក្រនេះគ្មាននារីមកពីភូមិភាគបូព៌ាទេ មានតែនៅរោងចក្រត្បូងពុណោះ ដល់ត្រង់ហ្នឹងនារីពីរនាក់នេះសួរខ្ញុំដេញដោល ខ្ញុំមិន

ហ៊ាននិយាយឬទេពក ខ្លាចនារីនោះសួរច្រើន ខ្ញុំក៏ធ្វើដំណើរមកទៀត ដល់ដើរតាមថ្នល់នេះ មានថ្នល់បែកច្រើនខ្ញុំក៏បានដើរត្រង់ទៅកើត ដល់មកកើតឆ្ងាយទៀតមានថ្នល់មួយបែកច្រើន ខ្ញុំក៏ឃើញថ្នល់មួយចេញពីត្បូង ទៅជើង ថ្នល់នេះធំ ហើយខ្ញុំបានចេញពីថ្នល់ធំទៀងឈោកបន្តិច ដល់ដើរបានបន្តិចបានជួបអ្នករបួស ដែលដេកនៅមន្ទីរពេទ្យ ៦ មករា ហើយខ្ញុំបានដើរមកជាមួយគាត់ដែរ ពេលនោះគាត់ទាំងអស់បានសួរខ្ញុំថា បងមកពីណាដែរ ខ្ញុំឆ្លើយថាខ្ញុំចេញពីពេទ្យនឹងដែរ ប៉ុន្តែខ្ញុំ សុំពេទ្យទៅលេងបងប្អូននៅខាងលិចណោះ រួចហើយខ្ញុំបានដើរទៅចូលមន្ទីរពេទ្យ ៦ មករាជាមួយគាត់ ពេលដែលដើរតាមផ្លូវមិនទាន់ចូលដល់កន្លែងពេទ្យផង ខ្ញុំបានសួរអ្នករបួសនោះថា បងមានឃើញឈ្មោះ វង់ ដែលត្រូវរបួសពេទ្យនឹងទេ ហើយវង់នេះគាត់ត្រូវរបួសបាក់ដៃខាងឆ្វេង ពេលនេះអ្នកទាំងអស់នោះឆ្លើយថា ខ្ញុំមិនដឹង ឯជាវង់មួយណាទេ ព្រោះអីវង់ច្រើនដែរ ហើយខ្ញុំក៏បានដើរចូលមកមន្ទីរពេទ្យ ។ ពេលមកដល់មន្ទីរពេទ្យ ៦ មករា ពេលបាយឈ្នួម ហើយខ្ញុំបានដើរទៅចូលហូបបាយជា មួយគេដែរ ក្រោយពីហូបបាយហើយខ្ញុំបានជួបឈ្មោះ វង់ ដែលទើបចេញពីហូបបាយដែរ ។ ហើយវង់បានហៅខ្ញុំទៅជាមួយគាត់ វង់ដេកពេទ្យនៅអាគារទី ២ ជាន់កណ្តាលពេលទៀងទៅដល់បានបន្តិច វង់ បានសួរខ្ញុំថា មិត្តឯងមកធ្វើអីកន្លែងនេះអត់សំបុត្រអញ្ជើង ខ្ញុំបានប្រាប់ទៅវង់វិញថា តាមចុំគាត់ប្រើឱ្យខ្ញុំមកយកការទកកន្លែងអង្គការនៅទីក្រុងនេះ វង់សួរខ្ញុំទៀតថា មិត្តសព្វថ្ងៃនេះនៅកន្លែងណា ខ្ញុំឆ្លើយប្រាប់គាត់វិញ ខ្ញុំនៅកន្លែងគេហៅ កប់ស្រូវ វង់សួរថា ចុះកម្លាំងយើងនៅទីនេះ : ច្រើនដែរអី ខ្ញុំបានប្រាប់ឈ្មោះមាន ធី- រ៉ា- វ៉ន- សុន- ទឿន- ឃិន យ៉ំន

ក្រោយពីខ្ញុំប្រាប់គាត់ហើយ ៗ វង់ បានសួរខ្ញុំថា មិត្តឯងមកធ្វើអី ខ្ញុំឆ្លើយប្រាប់ វង់វិញថា វ៉ុនឱ្យខ្ញុំមកយកការកន្លែងអង្គការ ដើម្បីមានផែនការវ៉ៃនៅក្នុងក្រុងនេះ ហើយវ៉ុនឱ្យខ្ញុំគូសផ្លង់ទៀត ឱ្យបានល្អិតដែលទៅឃើញ និយាយមិនទាន់ចប់-ផងស្រាប់តែពេទ្យមកយាមអ្នកជំងឺយួននោះ ដល់ពេលយប់ក៏មិនបាននិយាយគ្នាទៀត ដល់ព្រឹកឡើងបាយថ្ងៃ ទើបខ្ញុំចេញពីមន្ទីរពេទ្យ ៦ មករាទៀត ពេលដែលដើរចេញមក " វង់បានផ្តាំខ្ញុំថា បើឯងសំរេចតាមផែនការបាន ត្រូវមកប្រាប់គ្នាផងផង ពេលនោះខ្ញុំបានចេញពីមន្ទីរពេទ្យ ៦ មករា ដើរតាមផ្លូវចូលមាត់ទន្លេ - នហួត ដើរបានមួយសន្ទុះស្រាប់តែជួបអ្នកយាម គាត់អត់ផែកខ្ញុំទៀត ហើយខ្ញុំដើរទៅទៀតដល់មាត់របង ហើយនឹងមានផ្លូវចូល ស្រាប់តែអ្នកយាមមកចាប់ខ្ញុំតែម្តងនៅថ្ងៃទី ២០.១១.១៩៧៨ នេះ ហើយបញ្ជូនខ្ញុំមកដល់កន្លែងនេះតែម្តង ៗ

ខ្ញុំសូមបញ្ជាក់ ពេលយកការណ៍បានទាំងសព្វគ្រប់តាមផែនការដែលវ៉ុនដាក់មក ខ្ញុំគូសផ្លង់ហើយ នឹងក្តាប់សភាពការណ៍បានច្បាស់មិនទាន់ទៅកប់ស្ងួវវិញទេ គឺខ្ញុំត្រូវតែរត់ទៅនៅតំបន់របស់ខ្ញុំវិញ ពីព្រោះនៅកន្លែងនេះកម្លាំងតិចមិនដឹងធ្វើអីរួច ទៅណេះមានមេដឹកនាំស្រួលបួល នឹងមានកម្លាំងច្រើន ៗ ប៉ុន្តែផែនការរបស់ខ្ញុំត្រូវអង្គការចាប់បាន ផែនទីក៏មិនទាន់គូសបាន ភូមិសាស្ត្រក្តាប់មិនទាន់បានទៀត ៗៗ

ធ្វើនៅថ្ងៃទី ១.១២.៧៨

អ្នកសួរ

ឃួន . សំ

ធ្វើនៅថ្ងៃទី ១.១២. ៧៨

ហត្ថលេខា

ផែម.វី ហៅ ទឿន

## បញ្ជីកម្លាំងពាក់ព័ន្ធក្នុងប្រវត្តខ្ញុំ

១ - ឪពុកខ្ញុំ សែម — អតីតៈចោរលួចគោក្របី បច្ចុប្បន្នទៅសហករណ៍កោះ
កុក ស្រុកពាមជរ តំបន់ ២៤ ។

២ -- បងខ្ញុំ មី — អតីតៈធ្វើស្រែ បច្ចុប្បន្នទៅសហករណ៍កោះកុក ស្រុក
ពាមជរ តំបន់ ២៤ ។

៣ - មឿន — អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជនទៅសហករណ៍ទឹកវិល
ស្រុកពាមជរ តំបន់ ២៤ ។

៤ - វីន — បងខ្ញុំផែន ស្លាប់ហើយតាំងពីឆ្នាំ ១៩៧០ មកម្លេះ ។

៥ - ភួង — អតីតៈមេស្រុកបាភ្នំ រត់ចេញពីស្រុកបាភ្នំតាំងពីឆ្នាំ ៧៣
បច្ចុប្បន្នត្តាបមិនបាន ។

៦ - ណោ — អតីតៈអ្នកដើរទារពន្ធដារ កាលពីឆ្នាំ ៧៣ អង្គការ
ចាប់ទៅអប់រំ បច្ចុប្បន្នជាប្រជាជនទៅសហករណ៍ ឃុំ
បឹងវែង ស្រុកបាភ្នំ តំបន់ ៣៤ ។

៧ - ឈឿន — អតីតៈអ្នកលក់ដូរទៅស្រុកយួន កាលពីឆ្នាំ ៧០ប្រធានភូមិ
ស្វែរៀន បច្ចុប្បន្នជាប្រជាជនទៅសហករណ៍ភូមិស្វែរាន
ឃុំបឹងវែង ស្រុកបាភ្នំ តំបន់ ២៤ ។

៨ - តាយីវ — អតីតៈអ្នកទារពន្ធដាពីសង្គមចាស់ កាលពីឆ្នាំ ៧៣ស្លាប់
ហើយ ។

៩ - ផាន់ — អតីតៈចោរលួចគោក្របី បច្ចុប្បន្នប្រជាជនទៅស្រុក

ពាមជរ តំបន់ ២៤ ៗ

១០- សុន អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជនទៅភូមិទសីក្អក ឃុំបឹងដែង
ស្រុកបាភ្នំ តំបន់ ២៤ ៗ

១១- ម៉ុន អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជនទៅសហករណ៍ភូមិប្រ ស្រែ
ស្រុកពាមជរ តំបន់ ២៤ ៗ

១២- យូន អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជនទៅសហករណ៍ភូមិកោះកុក
ស្រុកបាភ្នំ តំបន់ ២៤ ៗ

១៣- មាន អតីតៈធ្វើស្រែ បច្ចុប្បន្នប្រជាជនទៅសហករណ៍ភូមិប្រ ស្រែ
ស្រុកបាភ្នំ តំបន់ ២៤ ៗ

១៤- ប្រក់ អតីតៈធ្វើស្រែ កាលពីឆ្នាំ ៧៣ឈឺស្លាប់ហើយ ៗ

១៥- មិត អតីតៈធ្វើស្រែ កាលពីឆ្នាំ៧៣មានគ្រួសារ បច្ចុប្បន្នទៅ
សហករណ៍ភូមិស្វាយភ្លោះ ស្រុកពាមជរ តំបន់ ២៤ ៗ

១៦- សាក់ អតីតៈធ្វើស្រែ កាលពីឆ្នាំ ៧១ទៅយុទ្ធជនភូមិដូចគ្នាបច្ចុប្បន្ន
ប្រជាជនទៅសហករណ៍ភូមិស្វាយភ្លោះ ស្រុកពាមជរ ៗ

១៧- ឆុន អតីតៈធ្វើស្រែ ឆ្នាំ ៧៣ទៅយុទ្ធជនភូមិដូចខ្ញុំ បច្ចុប្បន្នប្រជាជ
នទៅសហករណ៍ភូមិប្រ ស្រែ ស្រុកបាភ្នំ តំបន់ ២៤ ៗ

១៨- សាន់ អតីតៈធ្វើស្រែ បច្ចុប្បន្នស្លាប់ហើយ ៗ

១៩- ហាន អតីតៈធ្វើស្រែ បច្ចុប្បន្នស្លាប់ហើយ ៗ

២០- ភិន មុនអង្គការចាប់ប្រធានអនុសេនាធំ ទៅយោធាតំបន់២៤ ៗ

២១- ខុម មុនអង្គការចាប់ សមាជិកកងអនុសេនាធំយោធាតំបន់២៥ ៗ

២២- សាមគ្គី មុនអង្គការចាប់អនុប្រធាន អនុសេនាធំយោធាតំបន់២៥ ៗ

២៣- សាខុត មុនអង្គការចាប់ ប្រធានអនុសេនាធំ នៅយោធាតំបន់២៥ៗ

២៤- ឆ្នាំង អតីតៈធ្វើស្រែ បច្ចុប្បន្នធ្វើទ័ពនៅតំបន់ ២៥ មិនដឹង នៅ
អង្គភាពណាទេ ៗ

២៥- អោក អតីតៈធ្វើស្រែ បច្ចុប្បន្នអនុសង្កាត់ទ្រាក់ទីង តំបន់ ២៥ ៗ

២៦- ស្លឹក អតីតៈធ្វើស្រែ បច្ចុប្បន្ននៅសហករណ៍ភូមិតាពេជ ឃុំរាក់ ទីង
ស្រុកបាភ្នំ តំបន់ ២៥ ៗ

២៧- ចែត អតីតៈធ្វើស្រែ បច្ចុប្បន្ននៅវិប្បធម៌ឃុំរាក់ទីង បច្ចុប្បន្នអង្គ
ការចាប់ ៗ

២៨- ទឹម មុនអង្គការចាប់ប្រធានសង្កាត់រាក់ទីង តំបន់ ២៥ ៗ

២៩- យូន បច្ចុប្បន្នប្រជាជននៅសហករណ៍តាពេជខាងជើង ឃុំរាក់ ទីង
ស្រុកបាភ្នំ តំបន់ ២៥ ៗ

៣០- ម៉ង់ បច្ចុប្បន្នទៅនៅមន្ទីរឃុំរាក់ទីង ស្រុកបាភ្នំ តំបន់ ២៥ ៗ

៣១- ថន បច្ចុប្បន្ននៅយុវជនកងចល័តឃុំរាក់ទីង ស្រុកបាភ្នំ តំបន់២៥ ៗ

៣២- ចយ បច្ចុប្បន្នប្រជាជននៅសហករណ៍ឃុំរាក់ទីង ស្រុកបាភ្នំ តំបន់២៥

៣៣- សារិន ដ- ដ- ដ- ៗ

៣៤- ចែល មុនអង្គការចាប់ជាអនុប្រធានក្រុម យោធាតំបន់ ២៥ ៗ

៣៥- សាទាំន មុនអង្គការចាប់ប្រធានអនុសេនាតូច នៅយោធាតំបន់២៥ៗ

៣៦- ស៊ាប មុនអង្គការចាប់អនុប្រធានអនុសេនាតូច យោធាតំបន់២៤ ៗ

៣៧- សារឿន ប្រធានអនុសេនាតូច នៅវរៈសេនាតូច ៧០៣ វរៈសេនា
ធំ ២៧០ យោធាតំបន់២៤ ៗ

៣៨- ចិន ប្រធានក្រុម នៅអនុសេនាធំ០.២១ វរៈសេនាតូច៧០៣ -
វរៈសេនាធំ ២៧០ យោធាតំបន់ ២៤ ៗ

៣៩- ស៊ុម អនុប្រធានអនុសេនាតូច អនុសេនាធំ ០.២២ វរៈសេនាតូច
៧០៣ វរៈសេនាធំ ២៧០ យោធាតំបន់២៤ ៗ

៤០- ថន មេពួកនៅអនុសេនា ០.២០ វរៈសេនាតូច ៧០៣ វរៈសេ
នាធំ ២៧០ យោធាតំបន់ ២៤ ៗ

៤១- មឿន យុទ្ធជននៅអនុសេនា ០.២០ វរៈសេនាតូច ៧០៣ វរៈសេ
នាតូច ២៧០ យោធាតំបន់ ២៤ ៗ

៤២- សារីម ប្រធានអនុសេនាធំ នៅវរៈសេនាតូច ៧០៣ វរៈសេនា
ធំ ២៧០ យោធាតំបន់ ២៤ ៗ

៤៣- សារ៉ាន់ ប្រធានអនុសេនាតូច អនុសេនាធំ.០.២០ វរៈសេនាតូច៧០៣
វរៈសេនាធំ ២៧០ យោធាតំបន់ ២៤ ៗ

៤៤- សារឹម អនុសេនាវរៈសេនាធំ នៅយោធាតំបន់២៤ ៗ

៤៥- បងហួយ សេនាវរៈសេនាធំ នៅយោធាតំបន់ ២៤ ៗ

៤៦- អ៊ីប អនុសេនាវរៈសេនាតូច នៅយោធាតំបន់ ២៤ ៗ

៤៧- ឌី យុទ្ធជននៅអនុសេនាធំ ០.២០ វរៈសេនាតូច ៧០៣ វរៈសេ

នាធំ ២៧០ នៅយោធាតំបន់ ២៥ ។

៤៨ - ថន ប្រធានក្រុមនៅអនុសេនាធំ០.២០ វរៈសេនាចូត៧០៣វរៈសេនាធំ ២៧០ នៅយោធាតំបន់ ២៥ ។

៤៩ - ផាន មេពួកនៅអនុសេនាធំ ០.២១ វរៈសេនាតូច ៧០៣ វរៈសេនាធំ ២៧០ នៅយោធាតំបន់ ២៥ ។

៥០ - គៀន យុទ្ធជននៅអនុសេនាធំ ០.២១ វរៈសេនាតូច ៧០៣ វរៈសេនាធំ ២៧០ នៅយោធាតំបន់ ២៥ ។

៥១ - សាមុត ប្រធានអនុសេនាធំ ០.២០ វរៈសេនាធំ ៧០៣ វរៈសេនាធំ ២៧០ នៅយោធាតំបន់ ២៥ ។

៥២ - ង៉ាង យុទ្ធជននៅអនុសេនាធំ ០.២០ វរៈសេនាតូច ៧០៣ វរៈ-សេនាធំ ២៧០ នៅយោធាតំបន់ ២៥ ។

៥៣ - វ៉ុន កាលនៅយោធាតំបន់ ២៥ប្រធានអនុសេនាធំ បច្ចុប្បន្ននេះនៅកប់ស្រូវ ប្រធានអនុសេនាធំដែរ ។

៥៤ - វង់ នៅយោធាតំបន់ ២៥ប្រធានអនុសេនាតូច បច្ចុប្បន្ននេះ-ដេកពេទ្យនៅ ៦ មករា ។

៥៥ - ភិន កាលនៅយោធាតំបន់២៥យុទ្ធជន បច្ចុប្បន្ននៅកប់ស្រូវយុទ្ធជនដែរ ។

៥៦ - ធី កាលនៅយោធាតំបន់ ២៥ ជាសមាជិកអនុសេនាតូច បច្ចុប្បន្នយុទ្ធជននៅកប់ស្រូវ ។

៥៦ - រ៉ា  កាលនៅយោធាតំបន់ ២៥ អនុក្រុម  បច្ចុប្បន្ននេះនៅកប់ស្រូវ  ជាយុទ្ធជនធម្មតា ។

៥៧ - យ៉ិន  កាលនៅអង្គភាពជាមួយខ្ញុំ  ជាប្រធានក្រុមនៅយោធា - តំបន់ ២៥ បច្ចុប្បន្នជាយុទ្ធជននៅកន្លែងកប់ស្រូវ ។

៥៨ - សុន  កាលនៅយោធាតំបន់ ២៥ យុទ្ធជន  បច្ចុប្បន្ននៅកន្លែងកប់ស្រូវយុទ្ធជនដដែរ ។

៥៩ - ទៀន  កាលនៅយោធាតំបន់ ២៥ ជាយុទ្ធជន  បច្ចុប្បន្ននេះនៅ-កន្លែងកប់ស្រូង ជាយុទ្ធជនដដែល ។